PED

PARTNERSHIP
FOR ENVIRONMENT
AND DEVELOPMENT
ORGANIZATION

ការស្រាវជ្រាវបែបសកម្មភាព

# ផលវិបាកនៃការមើលរំលង អត្ថប្រយោជន៍ទៅវិញទៅមក រវាងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទ និងកិច្ចខិតខំប្រឹងប្រែងអភិរក្ស

អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍ

**ករណីសិក្សានៅតំបន់ដែនជម្រកសត្វព្រៃព្រះរការ**
**ប្រទេសកម្ពុជា**
**ឆ្នាំ២០២៥**

# ការស្រាវជ្រាវបែបសកម្មភាព

# ផលវិបាកនៃការមើលរំលងអត្ថប្រយោជន៍ទៅវិញទៅមក រវាងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទ

# និងកិច្ចខិតខំប្រឹងប្រែងអភិរក្ស

# ករណីសិក្សានៅតំបន់ដែនជម្រកសត្វព្រៃព្រះរការ ប្រទេសកម្ពុជា


www.ped-cambodia.org

Facebook: PED Cambodia | Email: ed@ped-cambodia.org



**Disclaimer:** របាយការណ៍សិក្សាស្រាវជ្រាវនេះត្រូវបានផលិតឡើងសម្រាប់អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍ (PED) ដោយទទួលបានជំនួយហិរញ្ញវត្ថុពីស្ថាប័ននេះ។ រាល់ការបញ្ចេញមតិយោបល់នៅក្នុងរបាយការណ៍នេះជារបស់អ្នកស្រាវជ្រាវ ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ PED ឡើយ។

# សេចក្តីថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវ និងការផលិតរបាយការណ៍សិក្សាបែបសកម្មភាព ក្រោមប្រធានបទ“ផលប៉ះពាល់នៃការមើលរំលងអត្ថប្រយោជន៍ទៅវិញទៅមករវាងការចិញ្ចឹមជីវិតបែបជនបទ និងកិច្ចខិតខំប្រឹងប្រែងអភិរក្ស” ករណីសិក្សានៅតំបន់ដែនជម្រកសត្វព្រៃព្រះរការប្រទេសកម្ពុជា” ដឹកនាំដោយអង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍ (PED)។

សូមថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅ ចំពោះក្រុមការងាររបស់ PED ដែលបានជួយគាំទ្រ និងសម្របសម្រួលក្នុងការចុះដំណើរការសម្ភាសន៍ ប្រមូលទិន្នន័យ នៅតំបន់គោលដៅ ជាមួយសហគមន៍ និងអង្គការពាក់ព័ន្ធ។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ ជាទុនមួយសម្រាប់PED (និងអង្គការដៃគូយុទ្ធសាស្ត្រពាក់ព័ន្ធ) ប្រើប្រាស់ដើម្បីឆ្លុះបញ្ចាំងយុទ្ធសាស្ត្ររបស់ស្ថាប័ន និងបណ្តាញសហគមន៍ ព្រមទាំងសង្គមស៊ីវិល ក្នុងការចូលរួមចំណែកធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍ និងវឌ្ឍនភាពបរិស្ថាន។

ជាចុងក្រោយ សូមថ្លៃអំណរគុណដល់ដៃគូពាក់ព័ន្ធនានាជាពិសេសសមាគមបណ្តាញយុវជនកម្ពុជា (CYN) អង្គការពន្លកខ្មែរ (PKH) សមាគមស្ត្រីជនបទដើម្បីក្សេត្របរិស្ថាន (RWAA), និងសមាគមអាដហុក (Adhoc) ដែលបានចំណាយពេលវេលាជួបពិភាក្សាជាមួយក្រុមសិក្សារបស់យើងខ្ញុំ ចែករំលែងព័ត៌មាន ឯកសារពាក់ព័ន្ធ និងបទពិសោធន៍ជាក់ស្តែងដែលបាននឹងកំពុងកើតមាននៅក្នុងសហគមន៍មូលដ្ឋាន ។ ទាំងនេះជាធាតុចូលសំខាន់ក្នុងរបាយការណ៍សិក្សាស្រាវជ្រាវរបស់យើងខ្ញុំ។

## មាតិកា ទំព័រ


អក្សរកាត់ ........ 6
អំពីអង្គការPED ........ 8
១. មូលន័យសង្ខេប ........ 9
២. សេចក្ដីផ្ដើម ........ 12
២.១ សារបាន និងបរិបទ ........ 12
២.២ ចំណោទបញ្ហាសម្រាប់ការស្រាវជ្រាវ ........ 15
៣.វត្ថុបំណងនៃការស្រាវជ្រាវ ........ 19
៤.វិធីសាស្ត្រស្រាវជ្រាវ ........ 20
៥.ដែនកំណត់ និងកង្វះខាតនៃការសិក្សា ........ 21
៦. លទ្ធផលនៃការសិក្សាស្រាវជ្រាវ ........ 23
៦.១ ស្ថានភាពនៃការអភិរក្សនៅតំបន់ព្រៃព្រះរការបច្ចុប្បន្ន ........ 23
៦.២ ស្ថានភាពជីវភាពនៅតំបន់ព្រៃព្រះរការ ........ 26
៦.២.១ វិស័យកសិកម្មមូលដ្ឋាន ........ 27
៦.២.២ ដំណាំឧស្សាហកម្ម ........ 34
៦.២.៣ គម្រោងគាំទ្រជីវភាពក្នុងក្របខ័ណ្ឌអង្គការអភិរក្ស និងអង្គការសង្គមស៊ីវិល ........ 36
៦.២.៤ សកម្មភាពជីវភាពបែបសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចកួយ ........ 38
៦.២.៥ ស្ថានភាពបំណុល ចំណាក ស្រុក ការអប់រំរបស់កុមារ និងយុវជន និងសម្ពាធលើស្ត្រី ........ 39
៦.៣ អត្ថប្រយោជន៍ទៅវិញទៅមក រវាងការចិញ្ចឹមជីវិតបែបជនបទ និងការអភិរក្ស ........ 43

៦.៤ បញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ដែលជះឥទ្ធិពលដល់ការអភិរក្ស និងនិរន្តភាពនៃការចិញ្ចឹមជីវិតបែបជនបទ ........ 46

៧. ការពិភាក្សាលទ្ធផលស្រាវជ្រាវ ........ 48

៧.១ ការបាត់បង់គម្របព្រៃឈើ និងការចូលរួមការពារព្រៃឈើ ........ 48

៧.២ ការមើលរំលងកិច្ចខិតខំប្រឹងប្រែងអភិរក្សរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ........ 51

៧.៣ និរន្តភាពនៃការចិញ្ចឹមជីវិតបែបជនបទរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ........ 54

៨. សេចក្តីសន្និដ្ឋាន ........ 56

៩. ការផ្តល់អនុសាសន៍ ........ 57

១០.ឯកសារយោង ........ 61

## អក្សរកាត់

AIPP: អង្គការជនជាតិដើមភាគតិចអាស៊ី

Adhoc: សមាគមសិទ្ធិមនុស្សនិងការអភិវឌ្ឍកម្ពុជា

CEEJA: បណ្ដាញ យុត្តិធម៌ ពលរដ្ឋ បរិស្ថាន

CNA: បណ្ដាញសកម្មភាពសហគមន៍

CPA: សហគមន៍តំបន់ការពារធម្មជាតិ

CIPO: អង្គការជនជាតិដើមភាគតិចកម្ពុជា

CIYA: សមាគមជនជាតិដើមភាគតិចកម្ពុជា

CYN: បណ្ដាញយុវជនកម្ពុជា

ELC: សម្បទានដីសេដ្ឋកិច្ច

FAO: អង្គការស្បៀងអាហារនិងកសិកម្ម នៃអង្គការសហប្រជាជាតិ

MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

MoE: ក្រសួងបរិស្ថាន

LCIPs: សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើម

ICIPP: វេទិកាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច

NTFPs: អនុផលព្រៃឈើ

PA: តំបន់ការពារធម្មជាតិ

PED: អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍ

PFCN: បណ្ដាញសហគមន៍ព្រៃឈើព្រះរការ)

PKH: អង្គការពន្លកខ្មែរ

PPRK: ព្រៃព្រះរការ

SDGs: គោលដៅអភិវឌ្ឍប្រកបដោយចីរភាព

SMP: អង្គការសន្សំម្លប់ព្រៃ

UNFCCC: អនុសញ្ញានៃក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

WCS: អង្គការសមាគមអភិរក្សសត្វព្រៃ

## អំពីអង្គការPED

អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍគឺជាស្ថាប័នមិនរកប្រាក់ចំណេញថ្មីមួយ ត្រូវបានចុះបញ្ជី និងទទួលស្គាល់ដោយក្រសួងមហាផ្ទៃនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ ដែលមានស្ថាបនិកជាក្រុមអ្នកការពារបរិស្ថានជួរមុខនៅក្នុងប្រទេសកម្ពុជា។ បេសកកម្មរបស់ពួកយើងគឺដើម្បីពង្រីកការចូលរួមរបស់សាធារណជននៅក្នុងកិច្ចការពារបរិស្ថាន លើកកម្ពស់សេរីភាពសម្តែងមតិ និងការពារដល់អ្នកការពារបរិស្ថាន និងសិទ្ធិមនុស្ស។ ថ្វីត្បិតតែពួកយើងជាស្ថាប័នថ្មី ក៏ប៉ុន្តែការងាររបស់ពួកយើងទទួលបាននូវការទទួលស្គាល់ពីសំណាក់ប្រព័ន្ធផ្សព្វ ផ្សាយក្នុងស្រុក និងអន្តរជាតិយ៉ាងទូលំទូលាយ តាមរយៈការចូលរួមចំណែករបស់ពួកយើងទៅកាន់សង្គម ដែលរាប់ចាប់តាំងពីឆ្នាំ២០១៨ នៅពេលដែលពួកយើងធ្វើការងារស្ម័គ្រចិត្តក្នុងនាមជាក្រុមយុវជនដើម្បីបរិស្ថាន។

យើងមានបេសកកម្មគាំពារ និងអភិវឌ្ឍន៍សមត្ថភាពរបស់បណ្តាញ សហគមន៍យុវជន និងប្រជាពលរដ្ឋ ដើម្បីពង្រឹងការចូលរួមក្នុង ការអភិវឌ្ឍសង្គមតាមបែបប្រជាធិបតេយ្យ និងបរិយាបន្ន។ ដើម្បីសម្រេចបាននូវបេសកម្មនេះ អង្គការPEDផ្តល់ជូននូវវគ្គបណ្តុះបណ្តាល កម្មវិធីបោះជំរំ សិក្ខាសាលា ដល់ក្រុមគោលដៅរបស់យើងដើម្បីឲ្យពួកគាត់យល់ដឹងអំពីសិទ្ធិជាមូលដ្ឋានរបស់ខ្លួន គោលនយោបាយគាំពារបរិស្ថាន ព្រមទាំងគោលការសំខាន់ៗនៃសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យផងដែរ។

អង្គការPEDក៏ផ្តល់ជំនួយបច្ចេកទេស ដល់អ្នកការពារបរិស្ថានជួរមុខ និងសហគមន៍មូលដ្ឋានផងដែរ ព្រមទាំងចុះឃ្លាំមើល និងចងក្រងនូវរបាយការណ៍ សហការរៀបចំសកម្មភាពតស៊ូមតិ ព្រឹត្តិការណ៍ និងការរៀបចំកម្មវិធីនានាទាំងកម្រិតអនឡាញ និងដោយផ្ទាល់។

## ១. មូលន័យសង្ខេប

គម្របព្រៃឈើធម្មជាតិ ដែលផ្តល់សុខុមាលភាពបរិស្ថាន សេដ្ឋកិច្ចសង្គម និងវប្បធម៌ ជាពិសេសសម្រាប់ទ្រទ្រង់ប្រព័ន្ធជីវចម្រុះដ៏កម្រ ព្រមទាំងគាំពារជីវភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងជនជាតិដើមភាគតិច ត្រូវបានសង្កេតឃើញថានៅតែបន្តថយចុះជាលំដាប់ ជាពិសេសនៅក្នុងតំបន់ការពារធម្មជាតិមួយចំនួននៃប្រទេសកម្ពុជា។ ដោយសង្កេតឃើញបែបនេះ ការសិក្សាស្រាវជ្រាវមានដែលចំណងជើងថា "ផលប៉ះពាល់នៃការមើលរំលងអត្ថប្រយោជន៍ទៅវិញទៅមករវាងការចិញ្ចឹមជីវិតបែបជនបទ និងកិច្ចខិតខំប្រឹងប្រែងអភិរក្ស" ត្រូវបានធ្វើឡើងដើម្បីពិនិត្យមើលពីស្ថានភាពជាក់ស្តែងអំពីចំណោទបញ្ហាចលករនេះ ដោយលើកយកតំបន់ដែនជម្រកសត្វព្រៃព្រះរការជាករណីសិក្សា។

ការសិក្សានេះនឹងចូលរួមចំណែកក្នុងការលាតត្រដាង នូវឫសគល់បញ្ហាដែលទាក់ទងទៅនឹងការបន្តថយចុះនៃគម្របព្រៃឈើនៅតំបន់ដែនជម្រកសត្វព្រៃព្រះរការ តាមរយៈការស្វែងយល់ពីអត្ថប្រយោជន៍ទៅវិញទៅមករវាងជីវភាពជនបទ និងកិច្ចខិតខំប្រឹងប្រែងអភិរក្សព្រៃព្រះរការ។ ការសិក្សានេះផ្តល់ការយល់ដឹងស៊ីជម្រៅទៅក្នុងរបៀបដែលសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ចាត់ចែងធនធានធម្មជាតិដើម្បីគាំពារប្រព័ន្ធអេកូឡូស៊ី និងលើកស្ទួយសុខុសមាលភាពសេដ្ឋកិច្ចមូលដ្ឋាន ស្របពេលដែលបន្តទទួលរងការគម្រាមកំហែងពីវិបត្តិព្រៃឈើ និងដីធ្លីជាប្រព័ន្ធថែមមួយកម្រិតទៀតផងដែរ។

ជាលទ្ធផល ការសិក្សានេះបានរកឃើញនូវចំណុចគន្លឹះ សំខាន់ៗដូចខាងក្រោម៖

- ក្រៅពីការគម្រាមកំហែងពីការថយចុះព្រៃឈើ និងវិបត្តិដីធ្លី ជីវភាពរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចកួយនៅតែផ្សារភ្ជាប់យ៉ាងជ្រាលជ្រៅ ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងអភិរក្ស ក្នុងដែនជម្រកសត្វព្រៃព្រះរការ ដែលបង្ហាញឱ្យឃើញនូវនិរន្តរភាពជីវភាពបែបជនបទមួយ ឆ្លុះបញ្ចាំងនៅក្នុង SDG1 (គ្មានភាពក្រីក្រ), SDG13 (សកម្មភាពអាកាសធាតុ) & SDG15 (ជីវិតនៅលើដី)។
- មានការរើសអើងប្រឆាំងការចូលរួមការពារព្រៃឈើដោយស្ម័គ្រចិត្ត (ដោយមិនប្រើប្រាស់ថវិការដ្ឋ) ពី បណ្តាញសហគមន៍ អង្គការសង្គមស៊ីវិល និងមហាជននានា នាំឱ្យមានការខាតបង់ប្រជាប្រិយភាពផ្នែកនយោបាយ និងសាមគ្គីភាពរវាងប្រជារាស្ត្រ ជាមួយរដ្ឋ។
- ដោយសារតម្រូវការដើម្បីគាំពារការចិញ្ចឹមជីវិត បណ្តាញសហគមន៍ការពារព្រៃឈើ បដិសេធន៍ការបោះបង់ចោលឆន្ទៈក្នុងការការពារព្រៃឈើនៅក្នុងដែនជម្រកសត្វព្រៃព្រះរការ។
- ស្របពេលដែល អនុផលព្រៃឈើជាប្រភពចំណូលតាមរដូវរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចកួយ កំពុងរងការគម្រាមកំហែងដោយការកាប់បំផ្លាញព្រៃឈើ ទំនាស់ដីធ្លីដ៏អូសបន្លាយនៅតែជាឧបសគ្គគួរឱ្យព្រួយបារម្ភរារាំងស្ថេរភាពនៃការផលិតស្បៀងអាហារ និងប៉ះពាល់ដល់ជីវភាពរបស់ពួកគាត់។
- អនុផលព្រៃឈើជាច្រើននៅក្នុងតំបន់ព្រៃព្រះរការ មានសក្តានុពលអាជីវកម្មគួរឱ្យកត់សម្គាល់ តែការប្រមូលផលរបស់សហគមន៍មូល

ដ្ឋាន និងជនជាតិដើមភាគតិច ត្រឹមតែសម្រាប់លក់ចេញ និងរកចំណូលតាមរដូវ រីឯការភ្ជាប់ទៅក្នុងការកែច្នៃ ឬសហគ្រិនភាព ដែលអាចកែច្នៃទៅជាទំនិញមានតម្លៃខ្ពស់ក្នុងទីផ្សារ នៅមានកម្រិតនៅឡើយ។

**អនុសាសន៍៖**

- ធ្វើការឆ្លុះបញ្ចាំងជាលក្ខណៈប្រព័ន្ធ និងឱ្យបានទៀងទាត់នូវវិធីសាស្ត្រនៃគម្រោងអភិវឌ្ឍន៍ និងអភិរក្ស ដោយពិចារណាដាក់បញ្ចូលនូវចរន្តនៃទំនាក់ទំនងរវាងជីវភាព និងការអភិរក្សបែបធម្មជាតិ ដែលបានរកឃើញ (នៅក្នុងការសិក្សានេះ) ថាជាគម្រូភាពមួយនៃនិរន្តរភាពជីវភាពនៅជនបទ ដែលស៊ីសង្វាក់ទៅនឹងគោលនយោបាយអភិវឌ្ឍន៍នានា ជាពិសេសគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs)។
- កិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយវិបត្តិព្រៃឈើ ត្រូវធ្វើឡើងទន្ទឹមគ្នា និងទំនាស់ដីធ្លី ជាពិសេសរវាងក្រុមហ៊ុនស្កររអំពៅចិន និងសហគមន៍រងគ្រោះ ដោយបញ្ហាទាំងពីរនេះ មានទំនាក់ទំនងគ្នាជាប្រព័ន្ធយ៉ាងជិតស្និត។
- កាត់បន្ថយឬលុបបំបាត់នូវតម្រូវការរដ្ឋបាលបែបការិយាល័យធិបតេយ្យដែលមិនចាំបាច់ ដើម្បីសម្រួលដល់ការចូលរួម របស់បណ្តាញសហគមន៍មូលដ្ឋាន អង្គការសមាគម និងសង្គមស៊ីវិល និងមហាជនទូទៅ (មិនចាំបាច់តែ CPA ប៉ុណ្ណោះទេទើបមានសិទ្ធិចូលរួម) ក្នុងការការពារ ឬល្បាតព្រៃ។
- សូមធ្វើឱ្យប្រាដកថាជនបង្គោល ឬតំណាងសហគមន៍ដែលមានស្រាប់ មានភាពជាតំណាងពិតប្រាកដ ក្នុងការសម្រេចចិត្តប្រកបដោយបរិ

យាបន្ន (អាចឆ្លុះបញ្ចាំងឆន្ទៈសមាជិកទាំងមូល ឬភាគច្រើនបាន និងមិនមានឧបសគ្គដោយសារការបកស្រាយ និងអនុវត្តច្បាប់ដែលមានភាពលម្អៀង)។ ជាពិសេសត្រូវផ្តល់អាទិភាព និងភាពថ្លៃប្រឌិតចំពោះការរួមបញ្ចូលសមាជិក បណ្តាញសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចឱ្យបានកាន់តែច្រើនដែលអាចធ្វើទៅបាន។

- សូមផ្តល់ការគាំទ្រប្រកបដោយអត្ថន័យ និងបរិយាបន្នដល់សហគ្រិនសហគមន៍ - ផ្តល់ទាំងផ្នែកបច្ចេកទេសកែច្នៃអនុផលព្រៃឈើ និងជំនាញក្នុងការវិភាគប្រព័ន្ធសេដ្ឋកិច្ចនយោបាយ ទីផ្សារ ចង្វាក់ផលិតកម្ម និងវិនិយោគ។ និងធ្វើការសម្របសម្រួលសហគ្រិនភាពសង្គម ឬសហគមន៍ឱ្យបានជិតដល់ ជាពិសេស ការកែច្នៃជ័រច្បោះឱ្យទៅជាផលិតផលសម្រាប់ប្រើប្រាស់ក្នុងស្រុកដោយមិនចាំឱ្យសហគមន៍ពឹងផ្អែកលើឈ្មួញកណ្តាល។

# ២. សេចក្តីផ្តើម

## ២.១ សារបាន និងបរិបទ

សហគមន៍ជនបទរួមទាំងជនជាតិដើមភាគតិចនៅទូទាំងពិភពលោកភាគច្រើនគឺជាប្រជាជនក្រីក្រ ដែលជានិច្ចកាលរស់នៅក្នុង ឬក្បែរប្រព័ន្ធអេកូឡូស៊ីធម្មជាតិមានតម្លៃ។ដូច្នេះការពង្រឹងជីវភាពជនបទ មិនត្រឹមតែចាំបាច់សម្រាប់ការកាត់បន្ថយភាពក្រីក្រប៉ុណ្ណោះទេ (SDG1: ពុំមានភាពភាពក្រីក្រ) ប៉ុន្តែវាក៏ដើរតួនាទីសំខាន់នៅក្នុងការអភិរក្សបរិស្ថានធម្មជាតិ (SDG15: ជីវិតលើដី) និងភាពធន់នឹងអាកាសធាតុ (SDG13:សកម្មភាពបរិស្ថាន)។ ចំណែកដែនជម្រកសត្វព្រៃព្រះរការនៃ

វាលទំនាបភាគខាងជើង ដែលឋិតនៅក្នុងខេត្តព្រះវិហារ នៃប្រទេសកម្ពុជា ដែលត្រូវបានក្រុមអ្នកអភិរក្សដាក់ឈ្មោះថាជា ឧទ្យានសេរាំងហ្គិតេ (Serengeti)[1] នៃតំបន់អាស៊ីអាគ្នេយ៍ ជាប្រព័ន្ធអេកូឡូហ្ស៊ីដ៏សំខាន់ សម្រាប់ទ្រទ្រង់ទាំងជីវចម្រុះ និងជីវភាពនៅតំបន់ជនបទដែលមានជនជាតិដើមភាគតិចកួយរស់នៅច្រើនបំផុត[2]។ សម្រាប់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចកួយ បានបញ្ជាក់ថាតំបន់ដែនជម្រកសត្វព្រៃនេះជាកន្លែងផ្តល់នូវធនធានចាំបាច់ ដូចជាអនុផលព្រៃឈើ (ជ័រច្បោះ ផ្សិតប្រភេទផ្សេងៗ បន្លែ ផ្លែឈើ ត្រី សាច់ ផ្កាព្រៃមានតម្លៃ ថ្នាំបុរាណនិងការដកហូតឈើសម្រាប់សាងសង់លំនៅឋានដោយនិរន្តរភាពតាមបែបប្រពៃណីជនជាតិដើមភាគតិច)ដែលជាប្រភពសំខាន់សម្រាប់អាហាររូបត្ថម្ភ ប្រាក់ចំណូល និងកេរដំណែលវប្បធម៌ប្រពៃណីដែលបានបន្សល់ពីបុព្វបុរសរៀងមក។

បើទោះបីជាតំបន់ព្រៃព្រះរការត្រូវបានចាត់ចូលជាផ្លូវការឱ្យទៅជាដែនជម្រកសត្វព្រៃស្ទើរតែ១ទសវត្សរ៍កន្លងទៅហើយក្តី ក៏តំបន់នេះបាននឹងកំពុងជួបប្រទះការគំរាមកំហែងឥតស្រាកស្រាន្ត រួមទាំងភាពធកល្វែងនៃការអនុវត្តច្បាប់ ដែលបណ្តាលឱ្យការកាប់ឈើដោយខុសច្បាប់ ឬដោយលក្ខណៈបំផ្លិចបំផ្លាញនៅតែបន្ត ការ

[1] Serengeti ជាឈ្មោះឧទ្យានជាតិដ៏ល្បីល្បាញមួយនៅក្នុងប្រទេសតង់ហ្សានី ទ្វីបអាហ្វ្រិក។
[2] ជនជាតិដើមភាគតិចកួយត្រូវបានគេរកឃើញថារស់នៅច្រើនបំផុតក្នុងខេត្តព្រះវិហារ និងខេត្តកំពង់ធំ (JUSHUAProject.Net) - មានចំនួនប្រមាណ៧០,៣០២ស្មើប្រមាណ ២៥.៣៩% ក្នុងប្រទេសកម្ពុជា (CIPO, 2022)



*រូបភាពទី 1 សកម្មភាពសហគមន៍ចុះល្បាតការពារដែនជម្រកសត្វព្រៃព្រះរការ  ©PED Cambodia, 2025*

រឹតត្បិតសិទ្ធិសេរីភាពរបស់អ្នកការពារព្រៃឈើ និងសិទ្ធិប្រើប្រាស់ដីស្រែចំការរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចនៅក្នុងតំបន់។ បញ្ហាប្រឈមទាំងនេះ មិនត្រឹមតែដាក់ប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ដែនជម្រកសត្វព្រៃព្រះរការ ទៅក្នុងគ្រោះថ្នាក់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានធ្វើឱ្យប៉ះពាល់ដល់ស្ថេរភាពរបស់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានដែលពឹងផ្អែកលើអនុផលព្រៃឈើដើម្បីរស់រានមានជីវិតផងដែរ។

ក្នុងខណៈពេលដែលការអភិរក្ស និងសុវត្ថិភាពក្នុងការចិញ្ចឹមជីវិតគួរតែគាំទ្រគ្នាទៅវិញទៅមក ទំនាក់ទំនងនេះជាញឹកញាប់ត្រូវបានមើលរំលង ឬក៏មិនត្រូវបានយកទៅពិចារណាឱ្យបានម៉ត់ចត់នៅក្នុងក្របខ័ណ្ឌគោល

នយោបាយដែលនាំទៅរកអស្ថេរភាព សេដ្ឋកិច្ច ការបាត់បង់ចំណេះដឹងបែបប្រពៃណីរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ព្រមទាំងការសឹករិចរឹលនូវប្រព័ន្ធជីវចម្រុះ។ ការដោះស្រាយនូវក្តីបារម្ភទាំងនេះ ទាមទារឱ្យមានវិធីសាស្ត្រជាយុទ្ធសាស្ត្រ ដើម្បីកែខៃទំនាក់ទំនងនៃកត្តាជីវភាពក្នុងមូលដ្ឋាន និងការអភិរក្សឱ្យទៅជាឱកាសសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ជាជាងទុកឱ្យវានៅជាប្រភពនៃទំនាស់ចាក់ស្រេះ។

## ២.២ ចំណោទបញ្ហាសម្រាប់ការស្រាវជ្រាវ

គម្រោងអភិវឌ្ឍន៍ និងអភិរក្ស នៅក្នុងយុគសម័យទំនើប ជានិច្ចកាលប្រព្រឹត្តិទៅ ដោយមិនសូវផ្តោតការយកចិត្តទុកដាក់ទៅលើស្ថានភាពស្មុគស្មាញដែលបង្កប់នៅក្នុងមូលដ្ឋាន។ ជាញឹកញាប់គម្រោងទាំងនេះធ្វើការសម្រួល និងកែប្រែបញ្ហាស្មុគស្មាញផ្នែកនយោបាយ[3] ឱ្យទៅជាបញ្ហាបច្ចេកទេស ដោយកែច្នៃកិច្ចអន្តរាគមន៍តាមរយៈភាពជាតំណាង និងការអនុវត្តដែលមិនសូវឆ្លុះបញ្ចាំងការពិតនៅមូលដ្ឋាន។ ជាលទ្ធផលចុងក្រោយ និន្នាការនេះបានក្លាយទៅជាគម្រូមួយដែល “ប្រឆាំងនឹងបញ្ហានយោបាយ” ដោយទាត់ចោលរាល់ភាពស្មុគស្មាញ នៃបរិបទសង្គម និងពិភពលោកជាក់ស្តែងនាពេលបច្ចុប្បន្ន។ ជាក់ស្តែងការអភិរក្សតំបន់ការពារធម្មជាតិ គឺជាទ្រឹស្តី និងការ

[3] នយោបាយក្នុងន័យទូលំទូលាយ មានដូចជា នយោបាយធនធានធម្មជាតិ នយោបាយទឹក នយោបាយដី ឬនយោបាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ ន័យនយោបាយជាសកលនេះ គ្របដណ្តប់វិសាលភាពទូលាយ ជាងការឱ្យនិយមន័យតូចចង្អៀត ដែលផ្តោតតែលើគណបក្សនយោបាយកាន់អំណាច និងបក្សជំទាស់។

អនុវត្តនាំយកមកពីទ្វីបអឺរ៉ុប ដែលជាគម្រោងអនុវត្តមួយ ចាប់ផ្តួចផ្តើមឡើងតាំងពីទសវត្សរ៍៧០ និងឆ្លងកាត់ការកែតម្រូវជាច្រើនលើកច្រើនសារ ចាប់តាំងពីការបណ្តេញប្រជាពលរដ្ឋមូលដ្ឋាន និងជនជាតិដើមភាគតិចចេញដើម្បីអនុវត្តគម្រោងអភិរក្ស រហូតដល់ការចាប់ផ្តើមគិតគូរខ្លះៗអំពីការចែករំលែកផលប្រយោជន៍ដល់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច តាមរយៈការលើកស្ទួយជីវភាព និងបំណិនជីវិតផ្សេងៗ។ គោលបំណងនៃការអភិរក្សជារឿងល្អ ដែលចង់ធ្វើឱ្យប្រសើរឡើងនូវ ទំនាក់ទំនងរវាងមនុស្ស និងធម្មជាតិ តាមរយៈការបង្កើតជាប្រព័ន្ធគ្រប់គ្រង ឬអភិបាលកិច្ច ក្នុងការការពារសត្វព្រៃ កសាងសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចឱ្យរឹងមាំ។ ជាអកុសល ធម្មជាតិនៃការអនុវត្តគម្រោងអភិវឌ្ឍន៍ និងអភិរក្សយកលំនាំពីក្រៅប្រទេសនេះអាចមានចរិតបែបផ្តាច់ការ ដោយសារវាពាក់ព័ន្ធនឹងការបណ្តេញ ចេញ រឹតត្បិតសេរីភាពប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ (បើទោះបីជាការប្រើប្រាស់នោះ មិនប៉ះពាល់ធ្ងន់ធ្ងរដល់រចនាសម្ព័ន្ធព្រៃឈើ ឬប្រព័ន្ធជីវៈចម្រុះក៏ដោយ)។ យ៉ាងណាមិញ អ្នកអនុវត្តគម្រោងព្យាយាមធ្វើផែនការ និងអនុវត្តន៍គម្រោងដ៏ស្មុគស្មាញនេះ ដោយមិនផ្សារភ្ជាប់ជាមួយការដោះស្រាយបញ្ហានយោបាយ។

ប្រហែលជាដូច្នេះហើយ ដែលនាំឱ្យសិទ្ធិសេរីភាពរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចដែលពឹងផ្អែកលើអនុផលព្រៃឈើដើម្បីរកចំណូលចិញ្ចឹមជីវិត ត្រូវបានរឹតត្បិត ប៉ុន្តែការកាប់បំផ្លាញឈើនៅតែអាចកើតមាន នៅពេលដែលមានការអនុវត្តគម្រោងអភិរក្សតំបន់ការពារធម្មជាតិចូលមកដល់។ ការរឹត

ត្បិតនេះអាចកើតឡើងដោយសារ គោលនយោបាយ និងការសម្រេចចិត្ត ដែលពាក់ព័ន្ធនឹងធនធានព្រៃឈើ ជាញឹកញាប់មានភាពលម្អៀងទៅកាន់ក្រុមមនុស្សដែលមានអំណាច (Patron-client relationships) ក្នុងខណៈពេលដែលសហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិច ប្រឈមមុខនិងច្បាប់ដែលមានលក្ខណៈរឹតត្បិតនិងមិនច្បាស់លាស់។

ជាក់ស្តែងគម្រោងអភិវឌ្ឍន៍ និងអភិរក្សកាន់តែច្រើនឡើងៗ ត្រូវបានបង្កើតឡើងដោយខ្វះការចូលរួមពីសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច (LCIPs[4] ) ប្រកបដោយអត្ថន័យ និងបរិយាបន្នទៅក្នុងការពិភាក្សាអំពីកត្តាជីវភាពរបស់ពួកគេ ដែលញ៉ាំងឱ្យមានភាពតានតឹងរវាងគម្រោងអភិវឌ្ឍន៍ និងអភិរក្ស ប្រឈមមុខជាមួយនឹងអ្នកប្រកបរបរចិញ្ចឹមជីវិតបែបសេដ្ឋកិច្ចជនបទ (ដែលជាទូទៅជាជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន)។ ជាក់ស្តែង ក្នុងខណៈពេលដែលគម្រោងវិនិយោគខ្នាតធំដូចជាឧស្សាហកម្មស្ករអំពៅ (ដែលត្រូវបានគេស្គាល់ថាធំជាងគេនៅទ្វីបអាស៊ី) បានប្រព្រឹត្តិទៅដោយខ្វះការទទួលខុសត្រូវចំពោះជីវភាពរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច គម្រោងរ៉េដបូក (REDD+) ក្នុងដែនជម្រកសត្វព្រៃព្រៃឡង់នៅជាប់ខាងគ្នានឹងព្រៃព្រះរការនោះ បានបង្ហាញគម្រូភាពមួយដែល

[4] សរសេរពេញជាភាសាអង់គ្លេសថា Local Communities and Indigenous Peoples (LCIPs)។ វេទិកាសហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិច (LCIPP) ត្រូវបានបង្កើតឡើងដោយ UNFCCC ក្នុងឆ្នាំ២០១៥ នៅទីក្រុងប៉ារីស កំឡុងពេលធ្វើ COP21 ដើម្បីជាការទទួលស្គាល់នូវចំណេះដឹង និងកិច្ចខិតខំប្រឹងប្រែង របស់ LCIPs ក្នុងការឆ្លើយតបនិងដោះស្រាយការប្រែប្រួលអាកាសធាតុ។

ហាក់ដូចជាបាន បរាជ័យ ជាបណ្តើរៗ រួចទៅហើយនៅក្នុងការកាត់បន្ថយការកាប់បំផ្លាញគម្របព្រៃឈើដែលជាឆ្អឹងខ្នងនៃការធ្វើអាជីវកម្មទីផ្សារកាបូន។ ភាពបរាជ័យនេះនៅតែកើតឡើង បើទោះបីជាមានកិច្ចសហការជិតស្និតរវាងស្ថាប័នរដ្ឋដែលទទួលខុសត្រូវ (ជាពិសេសក្រសួងបរិស្ថាន) និងអង្គការអភិរក្សផ្សេងៗ តាមរយៈគម្រោងអភិរក្សដែលភ្ជាប់ជាមួយការលើកស្ទួយជីវភាពមូលដ្ឋានក៏ដោយ។ ភាពឆកល្វែងនៅក្នុងការអនុវត្តគម្រោងការផ្សារភ្ជាប់មិនបានដិតដល់ជាមួយសហគមន៍មូលដ្ឋាន និងកង្វះអភិបាលកិច្ចល្អ ពេលខ្លះវាបានធ្វើឱ្យខកបំណងក្នុងការផ្សារភ្ជាប់រវាងការចិញ្ចឹមជីវិតបែបមូលដ្ឋានជាមួយ និងកិច្ចខិតខំប្រឹងប្រែងអភិរក្ស។

កង្វះតម្លាភាព និងគណនេយ្យភាពនៅក្នុងការបកស្រាយ និងការអនុវត្តច្បាប់នាំឱ្យខ្វះបរិយាបន្នក្នុងការចូលរួមការពារឬល្បាតព្រៃ ពីសំណាក់បណ្តាញសហគមន៍ដែលដឹកនាំដោយសហគមន៍មូលដ្ឋានខ្លួនឯង (ដែលឋិតនៅក្រៅក្របខ័ណ្ឌសហគមន៍តំបន់ការពារធម្មជាតិ) ព្រមទាំងអង្គការសង្គមស៊ីវិល និងមហាជនទូទៅដែលស្រលាញ់ និងចង់ចូលរួមការពារបរិស្ថាន។ សូម្បីការដើរល្បាតព្រៃរបស់សហគមន៍តំបន់ការពារធម្មជាតិខ្លួនឯង (CPA[5] ) ក៏មានវិសាលភាពតូចចង្អៀត មិនអាចចូលដល់ក្នុងដែនជម្រកសត្វព្រៃដែលមានសកម្មភាពកាប់ឈើនៅតែបន្តឥតឈប់ឈរ។ ភាពអសកម្មដែលមិនគួរកើតមាននេះមិនត្រឹមតែនាំឱ្យមានការរាំងស្ទះចរន្តសេដ្ឋកិច្ចនៅ

[5] Community Protected Area ត្រូវបានប្រជាពលរដ្ឋនៅមូលដ្ឋានហៅរត់មាត់ថាស៊ីភីអេ (CPA) បើទោះបីជាពួកមិនស្គាល់ពាក្យពេញជាភាសាអង់គ្លេសក៏ដោយ។

មូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានពន្យារឱ្យមានចលនាសង្គមក្នុងការប្រឆាំងតបតចំពោះការអនុវត្តច្បាប់ដែលខ្វះតម្លាភាព និងគណនេយ្យភាពនេះផងដែរ។

ការរឹតត្បិតការចេញចូលព្រៃរួមជាមួយនឹងកង្វះអភិបាលកិច្ចល្អ កំពុងបន្តប៉ះទង្គិចដល់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានគួរឱ្យកត់សម្គាល់ ដែលធ្វើឱ្យមានផលជះជាអវិជ្ជមានដល់លទ្ធភាពរបស់ពួកគេនៅក្នុងការគាំពារនូវការប្រមូលផលអនុផលព្រៃឈើបែបប្រពៃណី និងស្ថេរភាពសេដ្ឋកិច្ច។ ស្របពេលដែលកម្មវិធីអភិរក្សសំដៅស្វែងរកផលប្រយោជន៍ប្រព័ន្ធអេកូឡូស៊ីរយៈពេលវែង ទាំងព្រៃឈើ និងសេដ្ឋកិច្ចមូលដ្ឋាននៅតែបន្តទទួលរងគ្រោះថ្នាក់ដោយសារបញ្ហាដែលមិនទាន់បានដោះស្រាយរួចរាល់ ដូចជាការកាប់បំផ្លាញព្រៃឈើ កំសោយនៃការអនុវត្តច្បាប់ និងទំនាស់នានាលើការគ្រប់គ្រងធនធានធម្មជាតិជាដើម។ល។

## ៣.វត្ថុបំណងនៃការស្រាវជ្រាវ

ការសិក្សានេះ មានបំណងឆ្លើយនូវសំណួរ ថាតើការចិញ្ចឹមជីវិតបែបជនបទ និងកិច្ចខិតខំប្រឹងប្រែងអភិរក្សមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច នៅតំបន់ព្រៃព្រះរការ ហើយ តើការមើលរំលងទំនាក់ទំនងនេះ នាំឱ្យមានផលលំបាកអ្វីខ្លះ?

ដើម្បីឆ្លើយតបទៅនឹងសំណួរដ៏សាមញ្ញប៉ុន្តែចាំបាច់ខាងលើនេះ វត្ថុបំណងនៃការសិក្សាចំនួន៣ខាងក្រោមត្រូវបានកំណត់ឡើងរួមមាន៖

1) សិក្សាពីទំនាក់ទំនងនៃអត្ថប្រយោជន៍ទៅវិញទៅមករវាងការចិញ្ចឹមជីវិតបែបជនបទ និងកិច្ចខិតខំ

ប្រឹងប្រែងអភិរក្ស៖ ផ្ដោតលើរបៀបដែលសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចពឹងផ្អែកលើអនុផលព្រៃឈើសម្រាប់ការចិញ្ចឹមជីវិត និងកិច្ចខិតខំប្រឹងប្រែងអភិរក្ស ថាតើវាជះឥទ្ធិពលយ៉ាងដូចម្ដេចទៅលើសេដ្ឋកិច្ច និងសុខុមាលភាពសង្គមរបស់ពួកគេ។

2) កំណត់នូវបញ្ហាប្រឈមសំខាន់ៗ ពីការមើលរំលងទំនាក់ទំនងខាងលើនេះ៖ ស្វែងយល់ពីហានិភ័យជាក់លាក់ទាក់ទងនិងការសឹករិចរិលធនធានធម្មជាតិ ការបាត់បង់ជីវៈចម្រុះ និងភាពធន់របស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។

3) ឈ្វេងយល់ពីចំណេះដឹងមូលដ្ឋាន និងការផ្សារភ្ជាប់ជាមួយការអភិរក្ស៖ ពិនិត្យមើលរបៀបដែលការអនុវត្តបែបប្រពៃណីនិងការផ្តួចផ្តើមនានាដែលដឹកនាំដោយសហគមន៍ខ្លួនឯងចូលរួមយ៉ាងដូចម្ដេចទៅក្នុងការគ្រប់គ្រងធនធានធម្មជាតិដោយចីរភាព។

## ៤.វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវបែបសកម្មភាព (Action Research) នេះផ្ដោតសំខាន់លើវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ។ យើងធ្វើការប្រមូលទិន្នន័យ និងព័ត៌មានផ្សេងៗតាមរយៈ ការសំយោគឯកសារពាក់ព័ន្ធ និងបទសម្ភាសន៍ផ្ទាល់ និងតាមអនឡាញជាមួយភាគីពាក់ព័ន្ធ ព្រមទាំងការពិភាក្សាក្រុមជាមួយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចក្កួយ។

យើងបានសម្ភាសន៍អ្នកពាក់ព័ន្ធសំខាន់ៗសរុបចំនួន១២នាក់ (KIIs[6] ) ក្នុងនោះរួមមាន សហគមន៍មូលដ្ឋាន

[6] Key Informant Interviews

និងជនជាតិដើមភាគតិចតិចកួយសរុប ចំនួន៨នាក់ (ដែលមានស្ត្រីចំនួន៣នាក់ និងយុវជនចំនួន២នាក់) និង តំណាងអង្គការសង្គមស៊ីវិលចំនួន៤នាក់ (ស្ត្រី១នាក់) និងបុគ្គលិកមីក្រូហិរញ្ញវត្ថុចំនួន១នាក់ (អ្នកស្រលាញ់ភេទដូចគ្នា) ។ ក្រុមពិភាក្សា (FGDs[7] ) ចំនួន២ក្រុមដែលមានមនុស្សសរុប ១៥នាក់ (ស្ត្រី ៧នាក់) ក៏ត្រូវបានធ្វើឡើងជាមួយសហគមន៍មូលដ្ឋានដែលនៅជុំវិញតំបន់ព្រៃព្រះរការផងដែរ។ ការសម្ភាសន៍ និងក្រុមពិភាក្សានេះ ធ្វើតាមយុទ្ធសាស្ត្រសម្ភាសន៍ស៊ីជម្រៅបែបគុណភាព (In-Depth Interview) ក្នុងគោលបំណងប្រមូលព័ត៌មានពីភាគីពាក់ព័ន្ធ ដែលមានចំណេះដឹងក្នុងការវិភាគបែបស៊ីជម្រៅ ការចូលរួមសកម្មក្នុងកិច្ចការពារធនធានធម្មជាតិដែលជាអ្នកទទួលបានផលដោយផ្ទាល់ពីធនធានធម្មជាតិ ដែលអាចផ្តល់នូវការយល់ឃើញស៊ីជម្រៅទៅលើបញ្ហាប្រឈមបទពិសោធន៍ និងចំណេះដឹងដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវខាងលើ។

## ៥.ដែនកំណត់ និងគម្លាតនៃការសិក្សា

ការសិក្សាស្រាវជ្រាវនេះគ្របដណ្តប់ ស្រុកទាំង៣ដែលនៅជុំវិញដែនជម្រកសត្វព្រៃព្រះរការ រួមមានស្រុកឆែប ត្បែងមានជ័យ និងជាំក្សាន្ត។ ការជួបសម្ភាសន៍ផ្តោតជាចម្បងលើសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចកួយ មកពីស្រុកទាំង៣នេះ។ យ៉ាងណាមិញ ដោយសារពេលវេលាមានកំណត់ក្រុមសិក្សា អាចត្រឹមតែបានជួបសម្ភាសន៍ជាមួយតំណាងសហគមន៍មកពីស្រុកទាំង៣នេះតែប៉ុណ្ណោះ។

[7] Focus Group Discussions

ក្រៅពីសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចគួយ ក្រុមសិក្សាក៏បានជួបពិភាក្សាជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសមាគមនៅក្នុងខេត្តព្រះវិហារ និងអង្គការដែលមិនមានទីតាំងនៅក្នុងខេត្ត ប៉ុន្តែមានសហគមន៍គោលដៅនៅតំបន់ព្រៃព្រះរការ។ យើងក៏មានឱកាសបានជួបសំណេះសំណាលជាមួយជនជាតិដើមភាគតិចគួយជាមន្ត្រីឥណទានដែលបានកំពុងបំពេញការងារនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ហើយមានអតិថិជនគោលដៅ នៅក្នុងសហគមន៍១នៅជាប់នឹងតំបន់ព្រៃព្រះរការថែមទៀតផង។

ក្រុមសិក្សា មិនបានជួបសម្ភាសន៍ជាមួយមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ ឬអាជ្ញាធរមូលដ្ឋាន ជាពិសេសមន្ត្រីឧទ្យានុរក្សឡើយ ដោយសារខណៈពេលនោះ ទំនាក់ទំនងរបស់ពួកគាត់ ជាមួយអង្គការសង្គមស៊ីវិល និងក្រុមអ្នកការពារព្រៃព្រះរការ កំពុងឡើងកម្តៅ (កំពុងមានភាពមិនចុះសម្រុងគ្នាចំពោះទិន្នន័យ និងព័ត៌មានទាក់ទងនឹងការកាប់បំផ្លាញព្រៃឈើក្នុងដែនជម្រកសត្វព្រៃព្រះរការ)។

ដូច្នេះក្រុមសិក្សាស្រាវជ្រាវនេះក៏អាចត្រូវបានអាជ្ញាធរចាត់ទុកជាក្រុមអង្គការសង្គមស៊ីវិល និងអាចបង្កការរាំងស្ទះដល់ការសិក្សា។ ដូចនេះ ក្រុមសិក្សាបានពឹងផ្អែកលើការអង្កេត តាមដានសារព័ត៌មាន និងទស្សនៈរបស់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងអង្គការសង្គមស៊ីវិល ដែលបានជួបសម្ភាសន៍ ដើម្បីស្រាយបញ្ជាក់នូវចំណុចដែលត្រៀមសម្រាប់ស្វែងរកចម្លើយពីមន្ត្រីមានសមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋាន។ យ៉ាងណាមិញ ក្រុមសិក្សាទទួលស្គាល់ថា នៅមានភាពឆកល្វែង ក្នុងការទទួលបានទស្សនៈដោយផ្ទាល់ពីមន្ត្រីអនុវត្តច្បាប់និងអាជ្ញាធ

វពាក់ព័ន្ធទាំងនេះ អំពីការយល់ដឹង ការបកស្រាយ និងការអនុវត្តច្បាប់ និងគោលនយោបាយពាក់ព័ន្ធនានា ព្រមទាំង បញ្ហាប្រឈម និងផែនការយុទ្ធសាស្ត្រនាពេលអនាគត របស់ពួកគាត់ ឬស្ថាប័នគាត់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តច្បាប់នាពេលអនាគត។

## ៦. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៦.១ ស្ថានភាពនៃការអភិរក្សនៅតំបន់ព្រៃព្រះរការបច្ចុប្បន្ន

តំបន់ព្រៃព្រះរការត្រូវបានប្រែក្លាយជាដែនជម្រកសត្វព្រៃព្រះរការដោយអនុក្រឹត្យលេខ ៧៥ អនក្រ. បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ ដែលគ្របដណ្តប់ផ្ទៃដីប្រមាណ ៩០, ៣៦១ ហិកតា ជាប់ស្រុកចំនួនបី មានស្រុកឆែប ស្រុកជាំក្សាន្ត និងស្រុកត្បែងមានជ័យ។ ស្របពេលជាមួយគ្នាដែនជម្រកសត្វព្រៃឆែបក៏ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ៧៩ អនក្រ. បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦។ ក្រោមការដឹកនាំនិងគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដែនជម្រកសត្វព្រៃឆែប-ព្រះរការ ក៏ត្រូវបានបង្កើតឡើង តាមរយៈអនុក្រឹត្យលេខ១៧៤ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ដែលធ្វើឱ្យផ្ទៃដីកើនឡើងដល់ទំហំ ៣៤៧ ៥៦៨ ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង។ សូមបញ្ជាក់ថាដែនជម្រកសត្វព្រៃឆែប-ព្រះរការរ នេះបង្កើតឡើងដោយការច្របាច់បញ្ចូលគ្នារវាងដែនជម្រកសត្វព្រៃឆែប ព្រះរការ និងផ្នែកខ្លះនៃរបៀងអភិរក្សជីវៈចម្រុះ ឧត្តរ ដែលមានផ្ទៃដី ៦៧ ១៨០ ហិកតា (អនុក្រឹត្យ០៧ អនក្រ. បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ (សូមមើលផែនទីនៅក្នុងឧបសម្ព័ន្ធ11.1)។

តាមរយៈការសំយោគឯកសារបានរកឃើញថា មុនឆ្នាំ២០១៦ ព្រៃព្រះ



*រូបភាពទី 2 ដែនជម្រកសត្វព្រៃព្រះរការមើលពីលើអាកាស ©PED, 2025*

រការ គឺស្ថិតនៅក្រោមការគ្រប់គ្រង របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការចូលរួមការពារព្រៃពីបណ្តាញសហគមន៍ព្រៃព្រះរការ (PFCN[8]) ដែលពេលនោះ ការដកហូតឈើ និងអនុផលព្រៃឈើ គឺសម្រាប់តែបំពេញការប្រើប្រាស់ប្រចាំថ្ងៃក្នុងគ្រួសារ និងមានការលក់ដូរតិចតួចក្នុងតំបន់[9]តែប៉ុណ្ណោះ។ នេះដោយសារមិនទាន់មានតម្រូវការទីផ្សារខ្ពស់សម្រាប់ការទិញលក់ឈើ និងអនុផលព្រៃឈើនៅឡើយ។ ចាប់ពីឆ្នាំ២០១៦មក តម្រូវការទីផ្សារឈើ និងអនុផលព្រៃឈើ ទាំងក្នុងប្រទេស និងក្រៅ

[8] Preah Roka Forest Community Network

[9] កម្រិតមូលដ្ឋាន និងខេត្ត

ប្រទេសមានការកើនឡើងខ្ពស់ជាលំដាប់ ក្នុងឆ្នាំ២០១៦នេះដែរ ការវិនិយោគផ្ទាល់ពីបរទេស ដូចជាសម្បទានដីសេដ្ឋកិច្ចស្ករអំពៅ បានចាប់ដំណើរការទាំងមានភាពចម្រូងចម្រាស់ផ្នែកដីធ្លីជាមួយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។ បើទោះបីជាដែនជម្រកសត្វព្រៃកើតឡើងក្នុងឆ្នាំ២០១៦ ក្នុងគោលបំណងធានាឱ្យមានការថែរក្សាការពារជម្រកសត្វព្រៃ និងប្រព័ន្ធអេកូឡូស៊ី ក៏ដោយចុះ គេសង្កេតឃើញមានដេប៉ូអារឈើរីកដុះដាលដែលធ្វើឱ្យឆ្នាំនេះ ជាឆ្នាំដែលមាន អត្រាបាត់បង់គម្របព្រៃឈើច្រើន ជាងគេបំផុត មិនធ្លាប់មានបើប្រៀបធៀបជាមួយឆ្នាំកន្លងទៅនោះ ហើយមកទល់ឆ្នាំ២០២២ វាដើរតួលំដាប់លេខរៀងទី២ បន្ទាប់ពីឆ្នាំ២០២១ ដែលមានការផ្ទុះការកាប់ឈើខ្លាំងបំផុត។

នៅក្នុងការពិភាក្សាជាក្រុមក្នុងពេលសម្ភាសន៍ជាមួយអ្នកភូមិជនជាតិដើមភាគតិច ដែលកំពុងទទួលបានផលប្រយោជន៍ពីការប្រមូលអនុផលព្រៃឈើ បានបញ្ជាក់ប្រាប់ក្រុមសិក្សាស្រាវជ្រាវអំពីសកម្មភាពកាប់បំផ្លាញព្រៃឈើនៅតែបន្តកើតមានឡើងជារៀងរាល់ថ្ងៃ។ ការអះអាងនេះត្រូវបានគាំទ្រដោយរបាយការណ៍ឃ្លាំមើលលើកទី៣ របស់ CEEJA ដែលបានរកឃើញដោយប្រព័ន្ធផ្កាយរណបថាមាន ៤២៦ ហិកតានៃគម្របព្រៃឈើនៅដែនជម្រកសត្វព្រៃព្រះរការ ត្រូវបានបាត់បង់គិតមកទល់ឆ្នាំ២០២២ ស្របពេលដែល ១,៩២៨ ហិកតា ត្រូវបានបាត់បង់នៅក្នុងដែនជម្រកសត្វព្រៃឆែប ដែលបច្ចុប្បន្នត្រូវបានភ្ជាប់ជាមួយដែនជម្រកសត្វព្រៃព្រះរការផងនោះ។ បើទោះបីជាការបាត់បង់នេះបានថយចុះបើប្រៀបធៀបជាមួយឆ្នាំ

២០២១ ប៉ុន្តែវាគួរឱ្យភ្ញាក់ផ្អើលណាស់ ដែលការបាត់បង់គម្របព្រៃឈើនោះ មានទំហំរហូតដល់ ៨៥%នៃការបាត់បង់សរុប ៤, ៨៤៩ ហិកតា (សូមមើលឧបសម្ព័ន្ធ 11.2)។

លើសពីនេះទៅទៀត បើទោះបីជាអនុក្រឹត្យស្តីពីដែនជម្រកសត្វព្រៃព្រះរការនេះ បញ្ជាក់ពីការរួមបញ្ចូលសហគមន៍មូលដ្ឋាន និងសាធារណជនក៏ដោយ តែពួកគាត់បានលើកឡើងថា ពួកគាត់មិនអាចអនុវត្តន៍សិទ្ធិក្នុងនាមជាប្រជាពលរដ្ឋមូលដ្ឋាន និងជនជាតិដើមភាគតិច ក្នុងការចូលរួមការពារធនធានធម្មជាតិបានពេញលេញនៅឡើយទេ។ នេះដោយសារមានការរឹតត្បិត និងគម្រាមកំហែងពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈពាក្យសម្តី។

## ៦.២ ស្ថានភាពជីវភាពនៅតំបន់ព្រៃព្រះរការ



*រូបភាពទី 3 សហគមន៍កំពុងច្រូតស្រូវរួម ដែលជាការវិនិយោគរួមគ្នា @PED, 2024*

ប្រភពចំណូលសំខាន់ៗរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច បានមកពីការបង្កបង្កើនផលកសិកម្ម (ប្រមូលផលដំណាំ និងសត្វចិញ្ចឹម) និងការប្រមូលអនុផលព្រៃឈើ ដោយមានការពឹងផ្អែកលើប្រភពចំណូលពីការកាប់ឈើតិចតួចបំផុត (Sansom Mlup Prey, 2022)។ នៅក្នុងនេះក៏មានការជួយជ្រោមជ្រែងពីអង្គការមិនមែនរដ្ឋាភិបាល ផងដែរ ជាពិសេសអង្គការអភិរក្ស និងអង្គការ

សង្គមស៊ីវិលនៅក្នុងតំបន់។ ប្រជាពលរដ្ឋមូលដ្ឋានមួយចំនួនក៏ធ្លាប់ទទួលបានការងារ ពីរោងចក្រស្ករអំពៅដែលបានបង្កើតឡើងដោយក្រុមហ៊ុនចិនក្នុងការកែច្នៃជាស្ករអំពៅនាំចេញទៅក្រៅប្រទេស ជាពិសេសទៅប្រទេសឥណ្ឌា និងចិន។ វាជាដំណាំឧស្សាហកម្មអំពៅដែលធំជាងគេបំផុតនៅអាស៊ី។

### ៦.២.១ វិស័យកសិកម្មមូលដ្ឋាន

#### ៦.២.១.១ ដំណាំស្រូវ

ដំណាំស្រូវដើរតួសំខាន់ជាងគេនៅក្នុងការទ្រទ្រង់សុវត្ថិភាពស្បៀងអាហារក្នុងគ្រួសារ និងការលក់ដូរសម្រាប់ប្រាក់ចំណូលផងដែរ។ ស្រូវក្រហម ម្លិះ ដំណើប និងរំដួល ជាប្រភេទស្រូវដែលអ្នកភូមិដាំនាពេលបច្ចុប្បន្ន ហើយក្នុងចំណោមនេះរំដួលជាប្រភេទស្រូវដែលអ្នកភូមិនិយមដាំជាងគេបំផុត ដោយវាពេញនិយមនៅលើទីផ្សារ។ វាមានតម្លៃចាប់ពី ១,០០០ រៀល ដល់ ១,៨០០ រៀល ហើយអ្នកភូមិអាចរកចំណូលបានជាមធ្យម ១.២ លានរៀលក្នុង១ហិកតា។

#### ៦.២.១.២.ដំណាំស្វាយចន្ទី ពោត និងដំឡូងមី

ជាទូទៅដំណាំស្វាយចន្ទី ពោត និងដំឡូងមី ត្រូវបានដាំទ្រង់ទ្រាយធំ ជាលក្ខណៈចំការដាច់ដោយឡែកសម្រាប់លក់នៅទីផ្សារ អាស្រ័យលើទំហំដីដែលគាត់មាន។ ជាមធ្យមអ្នកភូមិអាចរកចំណូលបានពី ១.៥ លានរៀល ទៅ ១.៩ លានរៀល ក្នុងមួយហិកតាក្នុងមួយឆ្នាំពីដំណាំសេដ្ឋកិច្ចទាំងនេះ។

*ចំណាំ៖ ដើមដំឡូងមីមានរូបរាងស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងដើមដំឡូងឈើ ប៉ុន្តែភាពខុសគ្នាគឺនៅត្រង់ពណ៌នៃធាងរបស់វា។ ដំឡូងមីមានធាងពណ៌ស រីឯដំឡូងឈើមានធាងពណ៌ក្រហម។ ដំឡូងឈើភាគច្រើនត្រូវបានដាំនៅក្នុងសួនបន្លែនៅផ្ទះសម្រាប់ហូបខ្លួនឯ*

### ៦.២.១.៣ សត្វចិញ្ចឹមកសិកម្ម

ជាទូទៅសត្វចិញ្ចឹមសម្រាប់វិស័យកសិកម្ម មាន គោ ក្របី មាន់ទា ជ្រូក និងត្រី។ យ៉ាងណាមិញ បច្ចុប្បន្ននេះ គោលបំណងនៃការចិញ្ចឹមសត្វទាំងនេះ សម្រាប់លក់ដូរ និងកាប់សាច់បរិភោគនៅផ្ទះដោយខ្លួនឯង។ យើងសង្កេតឃើញជាពិសេស គោក្របី មិនត្រូវបានប្រើដើម្បីការភ្ជួររាស់ដូចពីអតីតកាលទៀតឡើយ។ ភាគច្រើនសកម្មភាពភ្ជួររាស់ ត្រូវបានធ្វើដោយត្រាក់ទ័រឬគោយន្ត។

### ៦.២.១.៤ អនុផលព្រៃឈើ

➢ ជ័រទឹកឬជ័រច្បោះ៖ ត្រូវបានដងចេញពីដើមត្រាច[10] និងដើមឈើទាល[11]។ ១កានចំណុះ30លីត្រអាចលក់បានពី ៧ម៉ឺនទៅ១០ម៉ឺនរៀល (PED, 2025)។ នៅក្នុងបទសម្ភាសន៍ជាមួយសមាជិកបណ្តាញសហគមន៍ព្រៃព្រះរការ ដែលមានដើមច្បោះជាង៨០០ដើម បានឱ្យដឹងថា គាត់អាចរកចំណូលបានជាមធ្យម ១.៤ ទៅ២លានរៀល ក្នុង១ឆ្នាំ ពីការដងជ័រច្បោះនេះ។ គេអាចដងវាបានទាំងរដូវប្រាំងនិងរដូវវស្សា ប៉ុន្តែរដូវវស្សាវាផ្តល់ជ័រល្អជាងរដូវប្រាំង ដែលពេលខ្លះអ្នកដងជ័រក៏ជួបបញ្ហាដើមច្បោះមិនមានទឹកជ័រផងដែរ។



*រូបភាពទី 4 ការដុតរន្ធច្បោះដើម្បីយកជ័រទឹក @PED,2021*

[10] ដើមត្រាចដែលអាចផ្តល់ជ័រទឹកបាន មាន៖ ត្រាចស និងត្រាចក្រហម។

[11] ដើមឈើទាលដែលអាចផ្តល់ជ័រទឹកមាន៖ ឈើទាលបាយ ឈើទាលប្រេង ឈើទាលបង្គួយ។

*ចំណាំ៖ ជាទូទៅម្ចាស់ដើមច្បោះប្រមូលជ័រច្បោះបានជារៀងរាល់ខែ ដោយការដុតភ្លើងនៅនឹងគល់ដើមច្បោះដែលគេបានចោះប្រហោងស្រាប់ដើម្បីបង្ហូរជ័រវា រួចទុកចោល ១ឬ២ថ្ងៃមុននឹងត្រឡប់មកដងជ័រទឹកពីដើមច្បោះនេះ។ យ៉ាងណាមិញ បើទោះបីជាដើមច្បោះអាចបញ្ចេញជ័រទឹកញឹកញាប់ប៉ុណ្ណាក៏ដោយ ម្ចាស់ ច្បោះខ្លះបានប្រាប់ឱ្យដឹងថា ដើមច្បោះមួយចំនួនចាប់ផ្តើមខ្សោះទឹកជ័រ ជាពិសេសនៅរដូវប្រាំង។*

- ផ្សិត៖ អ្នកភូមិនៅមូលដ្ឋាន បានឱ្យដឹងថា ពួកគាត់អាច រកចំណូលបានពីការ លក់ផ្សិត (ប្រភេទផ្សេងៗ[12]) ពី ២៥, ០០០ ទៅ ៤០, ០០០ រៀលក្នុង១គក និង ១.៤ លានរៀលក្នុង១ឆ្នាំ អាស្រ័យលើបរិមាណតិចច្រើនដែលអាចរកបាន។ ជាទូទៅប្រសិនបើមានផ្សិតលក់ច្រើន តម្លៃអាចធ្លាក់ចុះ ប៉ុន្តែផ្ទុយទៅវិញបើផ្សិតរកមិនសូវបាន ស្របពេលដែលមានតម្រូវការទីផ្សារកើនឡើងច្រើន ធ្វើឱ្យតម្លៃឡើងខ្ពស់វិញ។ អាចរកបាននៅរដូវវស្សាប៉ុណ្ណោះ។
- ទឹកឃ្មុំព្រៃ៖ ផ្តល់ចំណូលដល់ប្រជាពលរដ្ឋមូលដ្ឋាន ប្រមាណ ០.៤ លានរៀលក្នុងមួយឆ្នាំ។ អាចរកបាននៅរដូវប្រាំងប៉ុណ្ណោះ។
- ផ្កាអ្នគីដេព្រៃ និងផ្កាព្រៃមានតម្លៃផ្សេងៗទៀត៖ វាជាប្រភេទផ្កាព្រៃកម្រនៅក្នុងតំបន់ព្រៃព្រះរការនិងមានតម្លៃរហូតទៅដល់ ៤០ទៅ៦០ម៉ឺនរៀលក្នុងមួលគីឡូក្រាមដោយលក់ទៅឈ្មួញនៅប្រទេសថៃ តាមរយៈការលើកឡើងរបស់សហគម

[12] ផ្សិតប៉ក់ ផ្សិតឈើ និង ផ្សិតក្ងោក

ន៍។ ប៉ុន្តែអាចរកបាននៅរដូវប្រាំងប៉ុណ្ណោះ។

- ប្រភេទត្រី កង្កែប និងហ៊ីង៖ សត្វទាំងនេះក្រៅពីផ្តល់ជាម្ហូបអាហារប្រចាំថ្ងៃសម្រាប់អ្នកភូមិហើយ វាក៏ជាប្រភពចំណូលលតាមរដូវកាលមួយក្នុងចំណោមអនុផលព្រៃឈើដែលអ្នកភូមិចូលទៅរកក្នុងព្រៃផងដែរ។ ដែលអាចលក់បានតម្លៃចន្លោះពី៣ម៉ឺនរៀលទៅ៤ម៉ឺនរៀល។ អាចរកបាននៅរដូវវស្សា។

*ចំណាំ៖ អនុផលព្រៃឈើអាចនៅមានច្រើនទៀត ប៉ុន្តែអ្នកស្រាវជ្រាវលើកយកតែមុខដែលអ្នកផ្តល់បទសម្ភាសន៏បានលើកឡើង ជាពិសេសអនុផលព្រៃឈើដែលមានតម្លៃអាចលក់ដូរឬធ្វើអាជីវកម្មបាន។*

### ៦.២.១.៥ ការប្រមូលអនុផលព្រៃឈើ និងសក្តានុពលអាជីវកម្ម

ការប្រមូលផលអនុផលព្រៃឈើដែលមានសក្តានុពលអាជីវកម្មត្រឹមតែផ្តល់នូវចំណូលតាមរដូវកាលដោយការនាំចេញទៅលក់នៅខាងក្រៅតំបន់ប៉ុណ្ណោះ។ រីឯសហគ្រិនភាពសហគមន៏ ជុំវិញការកែច្នៃអនុផលព្រៃឈើ នៅមិនទាន់មានការផ្តួចផ្តើមជាក់លាក់ ឬគាំទ្របានដិតដល់នៅឡើយ។ នៅក្នុងការសិក្សានេះយើងខ្ញុំលើកយកតែអនុផលព្រៃឈើមួយមុខ ដែលមានសក្តានុពលអាជីវកម្មកែច្នៃខ្ពស់ និងជាអ្វីដែលអ្នកភូមិលើកឡើងញឹកញាប់ជាងគេ។

ផ្អែកលើការសម្ភាសន៏ជាមួយសហគមន៏មូលដ្ឋាន និងជនជាតិដើមភាគតិចកួយ ពីដើមឡើយ (២០ឆ្នាំមុន) ជ័រទឹក ត្រូវបានយកធ្វើជាសម្ភារៈប្រើប្រាស់ក្នុងគ្រួសារប៉ុណ្ណោះ (ដូចជាជ័រ



*រូបភាពទី 5 ស្ត្រីជនជាតិដើមភាគតិចក្កួយកំពុងដងជ័រទឹក ©PED, 2025*

ការបិតទូក ជញ្ជាំង និងរនៀបផ្ទះ ឬចន្លុះដុតបំភ្លឺ)។ចាប់ពីឆ្នាំ២០០៧ជ័រច្បោះចាប់ផ្តើមមានទីផ្សារនៅក្នុងតំបន់(កម្រិតស្រុកខេត្ត) ព្រមទាំងមានត្រូវការទីផ្សារនាំចេញទៅប្រទេសជិតខាងផងដែររហូតមកដល់ឆ្នាំ២០១៦។ ម្ចាស់ច្បោះដែលត្រូវបានសម្ភាសន៏ មួយចំនួនប្រាប់ថា បច្ចុប្បន្នឈ្មួញកណ្តាលដែលទិញជ័រច្បោះពីគាត់ទៅនោះ គឺយកទៅលក់បន្តនៅប្រទេសថៃ រីឯអ្នកខ្លះទៀតថាគេយកទៅលក់នៅប្រទេសវៀតណាម (សូមមើលឧបសម្ព័ន្ធ 11.3)។ យ៉ាងណាមុិញ ការនាំចេញទៅលក់ឆ្លងប្រទេសនេះ ជាទូទៅធ្វើឡើងដោយក្រៅផ្លូវការ មិនមានគោលការណ៏និងកំណត់ត្រាច្បាស់លាស់ឡើយគិតមកទល់ឆ្នាំ២០១៦ (Watkins et al, 2016)។ ប៉ុន្តែមកដល់ឆ្នាំ២០២២

ក្រសួងបរិស្ថានក៏បានសហការជាមួយគម្រោងព្រៃឡង់បៃតង បានចាប់ផ្តើមពិភាក្សា ជាមួយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច សេចក្តីព្រាងប្រកាសឱ្យមានគោលការណ៍គ្រប់គ្រងដើមច្បោះ ក្នុងគោលបំណងកំណត់បែងចែកតំបន់គ្រប់គ្រង និងការកំណត់ព្រំប្រទល់តំបន់ការពារ។

ក្នុងពេលសម្ភាសន៍ម្ចាស់ច្បោះដែលលក់ជ័រច្បោះទៅឈ្មួញកណ្តាលក៏មានការស្ទាក់ស្ទើរនៅក្នុងការឆ្លើយតប នៅពេលសួរថាតើជ័រច្បោះនេះគេទិញយកទៅលក់នៅឯណាបន្ត? ហើយគេយកទៅផលិតអ្វី ហេតុអ្វីក៏មានតម្លៃល្អបែបនេះ?

សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចកួយ ជាម្ចាស់កម្មសិទ្ធិនៃដើមច្បោះជាលក្ខណៈប្រពៃណី ហើយក៏ធ្វើការផ្ទេរបន្តមរតកទៅឱ្យអ្នកជំនាន់ក្រោយរហូតមកដល់បច្ចុប្បន្ន។ បច្ចុប្បន្នជ័រច្បោះ១កានចំណុះ៣០លីត្រអាចលក់បានពី ៧ម៉ឺនទៅ១០ ម៉ឺនរៀល (PED, 2025)។ នៅក្នុងបទសម្ភាសន៍ជាមួយសមាជិកបណ្តាញសហគមន៍ព្រៃព្រះរការ ដែលមានដើមច្បោះជាង ៨០០ដើម បានឱ្យដឹងថា គាត់អាចរកចំណូលបានជាមធ្យម ១.៤ ទៅ២លានរៀល ក្នុង១ឆ្នាំ ពីការដងជ័រច្បោះនេះ។ ម្ចាស់ច្បោះដែលត្រូវបានសម្ភាសន៍ភាគច្រើន (៣នាក់ក្នុងចំណោម៥នាក់ដែលមានដើមជ័រច្បោះ) ក៏មិនសូវដឹងច្បាស់ដែរថាតើ គេទិញជ័រច្បោះយកទៅកែច្នៃធ្វើអ្វីខ្លះនោះទេ។ ប៉ុន្តែមួយចំនួនតូចនៃអ្នកប្រមូលជ័រច្បោះបានប្រាប់ថាគេយកវាទៅចម្រាញ់ធ្វើជាផលិតផលជីវៈឥន្ធនៈ ម្សៅសាប៊ូ សារធាតុរំលាយ ឬសារធាតុក្លិនផ្សេងៗ ការ ថ្នាំលាប ជ័រកៅស៊ូ និងទឹកថ្នាំ ដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងជីវភាពប្រចាំថ្ងៃ។

ការសិក្សាមួយធ្វើឡើងនៅតំបន់ដែនជម្រកសត្វព្រៃភ្នំព្រិច បានរកឃើញថាអនុផលព្រៃឈើដែលអាចធ្វើការលក់ដូរបាន ដើរតួយ៉ាងសំខាន់ជាប្រភពចំណូលបឋម សម្រាប់គ្រួសាររស់នៅក្នុងតំបន់ការពារធម្មជាតិ។ តួយ៉ាងជ័រច្បោះកកនិងរាវ ផ្កាអូគីដេ និងទឹកឃ្មុំព្រៃ គឺជាអនុផលព្រៃឈើដែលមានបរិមាណពាណិជ្ជកម្មខ្ពស់បំផុត (Phaneth Chou, 2022) ប៉ុន្តែការប្រមូលអនុផលព្រៃឈើទាំងនេះដោយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចបច្ចុប្បន្ន គឺសម្រាប់តែលក់ឱ្យ ទៅទីផ្សារក្នុងមូលដ្ឋាន និងឈ្មួញកណ្តាលប៉ុណ្ណោះ។ ហើយអ្នកមួយចំនួនក៏មិនសូវចង់ធ្វើដំណើរឆ្ងាយដែរ ដូច្នេះពួកគេរីករាយនឹងលក់តាមរយៈឈ្មួញកណ្តាល។

### ៦.២.១.៦ ធនធានព្រៃឈើ

ធនធានព្រៃឈើ៖ តាមការអង្កេតក៏ដូចជាការសិក្សាស្រាវជ្រាវផ្សេងៗ មានប្រជាពលរដ្ឋក្នុងមូលដ្ឋានតិចតួចណាស់ដែលប្រកបរបរដកហូតធនធានព្រៃឈើ ពិសេសការកាប់ដើមឈើដើម្បីចិញ្ចឹមជីវិត ដោយមិនរាប់បញ្ចូលការរកអុសនិងសត្វព្រៃតូចតាចសម្រាប់ជាប្រភពប្រូតេអ៊ីនក្នុងគ្រួ-សារ។ បើទោះបីជាការដកហូតដោយប្រជាពលរដ្ឋមូលដ្ឋានមានតួលេខតិចតួច ចំណូលបានពីការដកហូតដើមឈើអាចបានរហូតដល់ ២.២ លានរៀលក្នុង ១ឆ្នាំ (សូមមើលឧបសម្ព័ន្ធ11.4)។ យ៉ាងណាមិញ របរនេះត្រូវការចំណាយច្រើន លើតម្លៃប្រតិបត្តិការ និងប្រេងឥន្ធនៈ រួមផ្សំនឹងភាពប្រថុយប្រថានក្នុងការចាប់ឃាត់ខ្លួន ដោយឧទ្យានុរក្សនិងអ្នកដើរល្បាត ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួង

បរិស្ថាន (Sansom Mlup Prey, 2022) ។

បើទោះបីជាប្រជាពលរដ្ឋមូលដ្ឋានពឹងផ្អែកប្រភពចំណូលតិចតួចពីព្រៃឈើ វាមិនមានន័យថាយើងទាត់ចោលនូវការពិតដែលមានការថយចុះគម្របព្រៃឈើដ៏គួរឱ្យព្រួយបារម្ភ ដូចបានរកឃើញនៅក្នុងរបាយការណ៍ឃ្លាំមើលលើកទី៣របស់បណ្តាញ "យុត្តិធម៌ ពលរដ្ឋ បរិស្ថាន[13]" ហៅកាត់ថា CEEJA ឡើយ (CEEJA, 2023) ។ យ៉ាងណាមិញ ការបាត់បង់ព្រៃឈើដ៏គំហុកនោះទំនងជាកើតឡើងដោយកម្លាំងជម្រុញពីខាងក្រៅ ដែលពាក់ព័ន្ធជាមួយនិងក្រុមហ៊ុនឯកជនធំតូច ដែលបង្កើតឱ្យមានទីផ្សារទិញលក់ឈើយ៉ាងគគ្រឹកគគ្រេងនៅក្នុងតំបន់នោះ ដូចមានរៀបរាប់នៅក្នុងផ្នែកបន្ទាប់។

### ៦.២.២ ដំណាំឧស្សាហកម្ម

ឧស្សាហ៍កម្មដំណាំស្ករអំពៅធំជាងគេនៅអាស៊ីបានចាប់ផ្តើមនៅក្នុងឆ្នាំ ២០១៦ ក្នុងទំហំដី ៤០, ០០០ ហិកតាក្នុងខេត្តព្រះវិហារ ដែលប្រតិបត្តិការដោយក្រុមហ៊ុនចិនឈ្មោះ រ៉ួយហ្វេង ឡាន ហ្វេង ហេង យូ ហេងរ៉ួយ និង ហេងណង (Rui Feng: 8841ha , Lan Feng: 9015ha, Heng You: 8959ha,Heng Riu:9119ha Heng Nong: 6488ha) (PHK, 2016)។ តិចឬច្រើនឧស្សាហកម្មនេះក៏ធ្លាប់បានផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋមូលដ្ឋានផងដែរ តាមរយៈការធ្វើការជាកម្ម

---

[13] ពលរដ្ឋ យុត្តិធម៌ បរិស្ថាន ឬ CEEJA មានទម្រង់ពេញថា "ការចូលរួមរបស់ពលរដ្ឋដើម្បី យុត្តិធម៌បរិស្ថានសម្រាប់ទាំងអស់គ្នា" ឬហៅជាភាសាអង់គ្លេសថា Citizens Engaged in Environmental Justice for All ។ គឺជាគម្រោងសកម្មភាពរយៈពេល៥ឆ្នាំ ដើម្បីបង្កើនប្រសិទ្ធភាពនៃការការពារព្រៃឈើ នៅកម្រិតមូលដ្ឋាន។ https://preylang.net/2024/02/01/ceeja-monitoring-report-no-3-in-khmer/

កររោងចក្រ និងធ្វើជាអ្នកលក់ដូរចំណីអាហារ ភេសជ្ជៈ ប្រេងសាំង និងអីវ៉ាន់ផ្សេងៗទៀតទៅឱ្យអ្នកធ្វើការរោងចក្រនោះ (Narin Sun, 2020)។ យ៉ាងណាមិញប្រតិបត្តិការដំណាំ ឧស្សាហ៍កម្មនេះក៏បាននាំមកនូវជម្លោះដីធ្លីដ៏រ៉ាំរ៉ៃជាមួយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចរាប់ម៉ឺននាក់ (CNA, PKH, CIYA, GRAIN, AIPP, 2017) ។ ទំនាស់នេះកើតឡើងចាប់តាំងពីពេលដែលក្រុមហ៊ុនទាំងនេះ បានចូលមកឈូសឆាយដីដាំអំពៅក្នុងឆ្នាំ ២០១២ ក្រោមរូបភាពដីសម្បទានសេដ្ឋកិច្ច ប៉ុន្តែវាបិតនៅលើដីកេរដំណែលដូនតារបស់ជនជាតិដើមភាគតិចកួយ ហើយដែលពួកគេកំពុងបង្ករបង្កើនផលកសិកម្មក្នុងពេលនោះផងដែរ។ បើទោះបីមានការអះអាងបែបនេះពីជនជាតិដើមភាគតិចកួយនៅក្នុងតំបន់នោះក្តី ដីនោះត្រូវបានចាត់ទុកថាជាដីសាធារណៈរបស់រដ្ឋ ហើយត្រូវបានធ្វើអនុប្បយោគកែប្រែទៅជាដីឯកជនរបស់រដ្ឋ រួចផ្តល់ទៅឱ្យក្រុមហ៊ុនចិនក្រោមកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច។

រោងចក្រឧស្សាហកម្មនេះត្រូវបានបញ្ឈប់ដំណើរនៅក្នុងឆ្នាំ ២០២១ ប៉ុន្តែបញ្ហាទំនាស់ដីធ្លីនៅតែបន្ត ដោយសារដីដាំដំណាំអំពៅ ដែលរដ្ឋបានផ្តល់សម្បទានទៅឱ្យក្រុមហ៊ុនចិនទាំងនោះ មិនទាន់ទទួលបានដំណោះស្រាយសមរម្យពីអាជ្ញាធរពាក់ព័ន្ធនៅឡើយទេ។ ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅ ប្រជាពលរដ្ឋមូលដ្ឋានមួយចំនួនបានត្រឡប់មកបន្តការធ្វើស្រែចំការលើដីរបស់ខ្លួនវិញ ក្រោយពេលក្រុមហ៊ុនផ្អាកដំណើរការ។ យ៉ាងណាមិញការវិលត្រឡប់នេះជាការប្រថុយប្រថានផងដែរ ព្រោះពេលខ្លះ មានការរារាំងពីអាជ្ញាធរមូលដ្ឋាន និងរងបណ្តឹង

ក្រោមហេតុផលថាវានៅជាដីរបស់ក្រុមហ៊ុនចិន។

### ៦.២.៣ គម្រោងគាំទ្រជីវភាពក្នុងក្របខ័ណ្ឌអង្គការអភិរក្ស និងអង្គការសង្គមស៊ីវិល

មានកិច្ចខិតខំប្រឹងប្រែងក្នុងការអភិរក្សធនធានធម្មជាតិ ពីអង្គការមិនមែនរដ្ឋាភិបាលផងដែរ ជាពិសេសអង្គការដែលមានទីតាំងផ្ទាល់នៅក្នុងខេត្ត។ ក្នុងចំណោមនោះ អ្នកសិក្សាបានលើកយកសកម្មភាពគម្រោងមួយចំនួនរបស់អង្គការពន្លកខ្មែរ (PKH) និងអង្គការសមាគមអភិរក្សសត្វព្រៃ (WCS) ដែលពាក់ព័ន្ធជាមួយប្រធានបទស្រាវជ្រាវខ្លាំង។

អង្គការពន្លកខ្មែរ (PKH) ជាអង្គការក្នុងតំបន់ដែលបានចូលរួមចំណែកក្នុងការអភិរក្សនិងពង្រឹងជីវភាពសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចតាមរយៈ ការជួយគាំទ្រសម្របសម្រួល និងពង្រឹងចំណេះដឹងទៅដល់ក្រុមផ្សេងៗនៅក្នុងសហគមន៍ (ដូចជាក្រុមសន្សំប្រាក់ ក្រុមចិញ្ចឹមសត្វ ក្រុមទឹកឃ្មុំព្រៃ ក្រុមជ័រចេញ្ញៈ ក្រុមផ្សិត ក្រុមបន្លែ ក្រុមផ្លែគុយ ។ល។) អំពីៈ

- ភាពជាសហគ្រិនមូលដ្ឋាន (តាមរយៈការសម្របសម្រួលឱ្យមានផ្សារសហគមន៍ចុងសប្តាហ៍ ដែលអាចឱ្យសហគមន៍យកផលិតផល អនុផលព្រៃឈើ មកដាក់លក់បាន)។

- ការដកហូតធនធានធម្មជាតិប្រកបដោយចីរភាព និង ចំណេះដឹងក្នុងការគ្រប់គ្រងថវិកា ចំណូលចំណាយ (financial literacy) និងការចូលទៅកាន់ទីផ្សារផងដែរ (access to market)។

ក្រៅពីនេះ PKH ក៏បាននឹងកំពុងសម្របសម្រួល គាំទ្រដល់ក្រុមសហគមន៍អេកូទេសចរណ៍ មួយចំនួនផង

ដែរ ដូចជាសហគមន៍អេកូទេសចរណ៍ទឹកធ្លាក់ព្រះនិមិត្ត ស្ថិតក្នុងស្រុកឆែប និងសហគមន៍អេកូទេសចរណ៍ថ្មគោល ស្ថិតក្នុងភូមិអូរកក់ ស្រុកត្បែងមានជ័យ ដែលមានសកម្មភាពកែច្នៃឧបករណ៍ និងសម្ភារៈផ្ទះបាយ និងវត្ថុអនុស្សាវរីយ៍ ចេញពីដើមទ្រាំង ដើម្បីលើកកម្ពស់ជីវភាព តាមរយៈការបណ្តុះបណ្តាលផ្នែកបច្ចេកទេសកែច្នៃ ពង្រឹងជំនាញបដិសណ្ឋាកិច្ច និងគាំទ្រការសង់ផ្ទះស្នាក់សម្រាប់ទេសចរណ៍ និងការល្បាតព្រៃ។

ទន្ទឹមនឹងនេះ អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) បានសហការជិតស្និតជាមួយក្រសួងបរិស្ថាន ក្នុងការចូលរួមចំណែកអភិរក្សសត្វស្លាបក្រោមកម្មវិធីការពារសំបុកសត្វស្លាប (Bird Nest protection program in northern plains of Cambodia), ដែលសត្វស្លាបទាំងនោះរួមមាន សត្វត្រយ៉ងយក្ស(Giant Ibis) សត្វក្រៀល (Sarus Crane) និងសត្វត្រដក់តូច (Lesser Adjutant)សត្វត្មាតប្រផេះ (White-rumpled Vulture) និងសត្វត្មាតក្បាលក្រហម(Red-headed Vulture) ជាដើម។ល។ WCS អនុវត្តន៍កិច្ចការពារនេះ ដោយការផ្សារភ្ជាប់ជាមួយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចផងដែរ ដែលការផ្សារភ្ជាប់នេះធ្វើឡើងតាមរយៈសហគមន៍តំបន់ការពារធម្មជាតិ (CPA) ដែលបង្កើតឡើងនៅក្រោមក្រសួងបរិស្ថាន។

អង្គការអភិរក្សនេះក៏ធ្វើការគាំទ្រ និងលើកស្ទួយជីវភាពសហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិចផងដែរ ឧទាហរណ៍គម្រោងស្រូវសត្វត្រយ៉ង ដែលមានសមាជិកចំនួន ៥៧៦គ្រួសារ នៅក្នុងតំបន់ការពារភ្នំគូលេនព្រហ្មទេព  តំបន់ការពារព្រៃព្រះរការ

ផែប បាននឹងកំពុងចូលរួមការពារសត្វព្រៃជាច្រើនប្រភេទ ដែលក្នុងនោះមានបក្សី២៦០ ប្រភេទ និងសត្វដំរី សត្វគោព្រៃ។ មិនត្រឹមតែប៉ុណ្ណោះបានរួមចំណែកលើកកម្ពស់ជីវភាពគ្រួសារដែលជាសមាជិកដាំស្រូវសត្វត្រយ៉ងដែលអាចទទួលបានជាមធ្យម ២,១២៦.៨៧គីឡូក្រាមក្នុងមួយហិកតា ដែលជាការរួមចំណែកដល់ជីវភាពរបស់សហគមន៍ឲ្យមានភាពប្រសើរឡើងតាមរយៈការលក់ស្រូវត្រយ៉ងដែលមានការធានាតម្លៃ។ យោងតាមសម្រង់សម្ដីប្រធានអង្គការសន្សំម្លប់ព្រៃលោកកែវសុជាតិបានលើកឡើងថា ប្រជាជនគ្រប់រូបដែលនៅជុំវិញតំបន់ព្រៃ ហើយមានបំណងចង់ចូលរួមសកម្មភាពអភិរក្សធនធានធម្មជាតិជាពិសេសសត្វ និងសត្វស្លាប គឺអាចចូលរួមបានដោយឥតគិតថ្លៃក្នុងការផលិតស្រូវដែលមានគុណភាព និងមានតម្លៃខ្ពស់ជាងតម្លៃស្រូវធម្មតាពី២០% ទៅ៣០% និងពេលខ្លះអាចរហូតដល់ ៦០%។

### ៦.២.៤ សកម្មភាពជីវភាពបែបសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចក្លួយ

ក្រៅពីការគាំទ្រតាមរូបភាពការអនុវត្តគម្រោង ការពារធនធានធម្មជាតិ និងពង្រឹងជីវភាព តាមរយៈស្ថាប័នរដ្ឋ និងអង្គការសង្គមស៊ីវិល យើងក៏សង្កេតឃើញមានសកម្មភាពប្រកបរបរចិញ្ចឹមជីវិតជាក្រុមមួយចំនួន ដែលដឹកនាំដោយសហគមន៍ខ្លួនឯង និងសកម្មភាពការពារវប្បធម៌ប្រពៃណីផ្សេងៗទៀត។ សកម្មភាពនេះជាទូទៅត្រូវបានអង្កេតឃើញថាជាសកម្មភាពសាមញ្ញធម្មតា តាមរបៀបអ្នកជនបទ និងជនជាតិដើមភាគតិច ប៉ុន្តែវាជាការអនុវត្តល្អជាលក្ខណៈប្រពៃណី និងប្រព្រឹត្តទៅដោយធម្មជាតិ ដែលជាឱ

កាសដ៏ល្អសម្រាប់ផ្សារភ្ជាប់ទំនាក់ទំនង កសាងការជឿទុកចិត្ត ការពិភាក្សាស្វែងរកដំណោះស្រាយ និងឈានទៅរកសាមគ្គីភាពក្នុងចំណោមសមាជិកសហគមន៍ចំនួនច្រើន។ ឧទាហរណ៍ ការបង្កាត់ពូជស្រូវរួមគ្នា ជាដំណើរការនៃការចូលរួមអភិរក្សគ្រាប់ពូជ និងផ្លាស់ប្តូរកម្មវិធី ដែលគាំទ្រ ការពង្រឹងអំណាចសហគមន៍ និងអភិរក្សជីវៈចម្រុះដ៏សំខាន់ (FAO and ICRISAT, 2015)។ វាមិនត្រឹមតែជាការផ្សារភ្ជាប់តែតំណាងសហគមន៍ដែលជាអាជ្ញាធរមូលដ្ឋាន ឬចាស់ព្រឹទ្ធាចារ្យប្រពៃណីមួយចំនួនតូចប៉ុណ្ណោះទេ។ ការអនុវត្តនេះត្រូវបានក្រុមសិក្សាយើងខ្ញុំចាត់ទុកថាជាផ្នែកមួយដ៏សំខាន់ ដែលរំលេចឱ្យឃើញនូវទម្រង់នៃនិរន្តភាពជីវភាពបែបជនបទឬបែបប្រពៃណីមូលដ្ឋាន និងជនជាតិដើមភាគតិច ដោយសារសកម្មភាពទាំងនេះបានបង្ហាញឱ្យឃើញនូវបញ្ហា និងកម្លាំងចលករ ដែលជាទូទៅកប់ជ្រៅនៅក្នុងរចនាសម្ព័ន្ធសង្គម វប្បធម៌មូលដ្ឋាន និងជនជាតិដើមភាគតិច ហើយវាជាអ្វីដែលអ្នកអនុវត្តន៍គម្រោងអភិវឌ្ឍន៍ និងអភិរក្សចាត់ទុកថាជារឿងស្មុគស្មាញ ហើយជានិច្ចកាលគេមើលរំលង (Sarah M. & Sango M., 2015) ។ នៅពេលដែលការរកទទួលទាន មិនត្រឹមតែប្រព្រឹត្តទៅជាលក្ខណៈបុគ្គលដាច់ដោយឡែកពីគ្នា ប៉ុន្តែជាក្រុម ជាលក្ខណៈសហគមន៍ ឬសមូលហភាព ការរកទទួលទានឬការចិញ្ចឹមជីវិតនោះទំនងជាមានស្ថេរភាព ភាពធន់ និងឈានទៅរកនិរន្តភាព។

## ៦.២.៥ ស្ថានភាពបំណុល ចំណាកស្រុក ការអប់រំរបស់កុមារ និងយុវជន និងសម្ពាធលើស្ត្រី

ស្របពេលមានការថយចុះព្រៃឈើ និងបញ្ហាដីធ្លី បញ្ហាសង្គមគួរឱ្យ

កត់សម្គាល់មួយចំនួន ដូចជាការជំពាក់បំណុល ចំណាកស្រុក កុមារនិងយុវជនបាត់បង់ឬបោះបង់ការសិក្សា សម្ពាធការងារផ្ទះសម្រាប់ស្ត្រីមេផ្ទះកើនឡើង។ តាមរយៈការជួបសម្ភាសន៍ និងធ្វើក្រុមពិភាក្សាទល់មុខជាមួយភាគីពាក់ព័ន្ធ សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចក្តួយ ដែលជាស្ត្រីយុវជនតំណាងអ្នកស្រឡាញ់ភេទដូចគ្នា និងអង្គការសង្គមស៊ីវិល ក្នុងស្រុកមួយចំនួន ពួកគាត់បានលើកឡើង ដូចៗគ្នាអំពីបញ្ហាប្រឈមដែលបានកើតឡើង និងកំពុងកើតមានឡើងនៅក្នុងសហគមន៍របស់ពួកគាត់ ក្រោយពេលដែលមានការថយចុះព្រៃឈើ និងទំនាស់ដីធ្លីរ៉ាំរ៉ៃ ជាង១ទសវត្សរ៍កន្លងមកនេះ។ ពួកគាត់បានលើកឡើងពីផលលំបាកជាច្រើន ដោយក្នុងនោះគាត់បានលើកឡើងថា ដោយសារតែការបាត់បង់ព្រៃឈើ (ព្រៃឈើបាត់បង់នោះនាំឱ្យអនុផលព្រៃឈើក៏បាត់បង់ផងដែរ) និងការរឹតត្បិតសិទ្ធិសេរីភាព ក្នុងការចូលរួមអាស្រ័យផល ដូចជាការធ្វើស្រែចំការដែលជាកម្មសិទ្ធិរបស់គាត់ តាំងពីដូនតា។ ការបាត់បង់ឱកាសក្នុងការចូលទៅអាស្រ័យផល ដីធ្លីដើម្បីធ្វើ ស្រែចំការដងជ័រច្បោះ បានធ្វើឱ្យសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច មិនអាចមានលទ្ធភាព បញ្ជូនកូនទៅសាលា (យុវជនភាគច្រើនបោះបង់ការសិក្សាដោយសារខ្វះលទ្ធភាព) ចំណាកស្រុកទៅធ្វើជាកម្មករសំណង់ កម្មករតាមចម្ការនៅខេត្តផ្សេងៗ ក្រៅពីសហគមន៍ ដូចជាប្រទេសថៃ ចិន និងម៉ាឡេស៊ីដែលចំណាកស្រុកខ្លះ ជាការប្រថុយប្រថាន។ តាមរយៈការលើកឡើងរបស់ក្រុមគោលដៅ ក្រុមសិក្សាស្រាវជ្រាវបានសម្ភាសន៍ ការចំណាកស្រុក វាគឺជាបញ្ហាមួយដែលបង្កផលលំបាកដល់ស្ត្រី និងកុមារដែលត្រូវរស់

នៅបែកគ្នា ហើយស្ត្រីទៀតសោធ ត្រូវរ៉ាប់រងកិច្ចការផ្ទះផ្ទះម្នាក់ឯង ពេលប្តីមិននៅ និងកុមារខ្លះមិនទទួលបានការអប់រំដោយសារឪពុកម្តាយនាំធ្វើការចំណាក ស្រុកជាមួយខ្លួន។ មានគ្រួសារខ្លះទៀតត្រូវប្តូរលំនៅឋាន ទៅរស់នៅកន្លែងផ្សេងៗដោយសារបញ្ហាបំណុល។

តាមរយៈការចុះទៅស្រាវជ្រាវ និងជួបសម្ភាសន៍ ជាមួយតំណាងស្ថាប័នមីក្រូហិរញ្ញវត្ថុ។ បានរកឃើញថាមានទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុ ធនាគារ និងអ្នកចងការប្រាក់ក្រៅផ្លូវការ (ដែលគេស្គាល់ថាជាអ្នកចងការប្រាក់អាទិត្យ ឬថ្ងៃ)សរុបប្រមាណជិត១០ស្ថាប័ន (សូមមើលឧបសម្ព័ន្ធ 1.5)។ គាត់បានលើកឡើងថា ការជំពាក់បំណុលរបស់ប្រជាពលរដ្ឋ មានការកើនឡើងក្នុងរយៈពេលជិតមួយទសវត្សរ៍កន្លងមកនេះ ហើយកម្ចីភាគច្រើន មានគោលបំណងយកទៅធ្វើទុនរកស៊ី (ធ្វើអាជីវកម្ម) ទិញឧបករណ៍សម្រាប់ធ្វើស្រែចំការ ផ្គត់ផ្គង់ការចំណាយប្រចាំថ្ងៃ សង់លំនៅឋាន ទិញយានជំនិះ និងរៀបចំពិធីបុណ្យទានផ្សេងៗរួមទាំងរៀបចំពិធីអាពាហ៍ពិពាហ៍ផងដែរ។ អ្នកផ្តល់បទសម្ភាសន៍ដែលជាមន្ត្រីឥណទាននៅធានាគារមួយកន្លែង ហើយដែលមានឈាមជ័រជាជនជាតិដើមភាគតិចកួយដែរនោះ បានប្រាប់ថា កម្ចីនៅក្នុងភូមិគោលដៅរបស់គាត់កន្លងមក ភាគច្រើនអតិថិជន (ដែលជាអ្នកភូមិជនជាតិដើមភាគតិចកួយ) អាចសងត្រឡប់វិញបាន មិនមានបញ្ហាធំដុំទេ។

ប្រជាពលរដ្ឋក្នុងមូលដ្ឋានដែលធ្លាក់ទៅក្នុងអន្ទាក់បំណុល គឺដោយសារពួកគាត់មានបំណុលច្រើនកន្លែង ដោយយកកម្ចីពីកន្លែងថ្មីៗទៅដោះបំណុលចាស់ ហើយឈានដល់ការខ្ចីប្រាក់ប្រចាំសប្តាហ៍ ឬសូម្បីប្រចាំ

ថ្ងៃ (បង់ការប្រចាំថ្ងៃឬប្រចាំសប្តាហ៍ ហើយចំនួនប្រាក់កម្ចីដើមនៅដដែល យូរៗទៅ ការប្រាក់ឡើងស្មើដើម)។ អ្នកចងការប្រាក់ប្រភេទនេះ មិនមានប្រភពច្បាស់លាស់ ខ្ចីឆាប់បាន មិនទាមទារក្រដាស់ស្នាមច្រើន និងសួរដេញដោយពីគោលបំណងនៃការខ្ចីឡើយ ប៉ុន្តែការប្រាក់ខ្ពស់។ តាមរយៈការសម្ភាសន៍ អ្នកភូមិបានប្រាប់ឱ្យដឹងថា អ្នកដែលធ្លាក់ក្នុងអន្ទាក់បំណុលភាគច្រើនជាអ្នកដែលខ្ចីលុយទៅរកស៊ីកាប់ឈើ ដោយយកទៅទិញគោយន្តដើម្បីដឹកឈើឲ្យឈ្មួញឬថៅកែឈើ។ អ្នកខ្លះដឹកឈើបានលុយមួយជើងពីរជើងដំបូង ដល់ជើងក្រោយមក ត្រូវមន្ត្រីឧទ្យានុរក្សចាប់យកអស់។ អស់ទាំងរបស់ហើយ ត្រូវទទួលបណ្តឹង ដែលត្រូវរកលុយទៅដោះស្រាយទៀត។

អ្នកភូមិដែលបានចូលរួមក្រុមពិភាក្សា និយាយថាជាទូទៅពួកគាត់ខ្ចីបំណុលដរាបណាគាត់មានការចាំបាច់ហើយ គិតថាមានលទ្ធភាពសង។ ក្នុងចំណោមអ្នកចូលរួមសម្ភាសន៍នោះមានម្នាក់ទើបតែយកកម្ចីពីធនាគារចំនួន២លានរៀល ដោយគាត់មានធុរៈរៀបចំអាពាហ៍ពិពាហ៍កូនប្រុសរបស់គាត់។ គាត់សងត្រឡប់ទៅវិញប្រចាំខែក្នុង១ខែ ១៤ម៉ឺនរៀល គាត់មានជំនឿចិត្តថាអាចសងត្រឡប់ទៅវិញបានតាមរយៈចំណូលពីជ័រច្បោះរបស់គាត់ដែលគាត់អាចរកបាន ១ខែជាមធ្យម១៥ទៅ ២០ម៉ឺនរៀល ដូច្នេះគាត់អាចបង់ធនាគារខ្លះនិងសល់ខ្លះសម្រាប់ចំណាយផ្សេងៗ។

ការខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុឬធនាគារ ដែលឆ្លងកាត់ការសិក្សាពីគោលបំណងនៃការខ្ចី លទ្ធភាពសងត្រឡប់ច្បាស់លាស់ អ្នកខ្ចីប្រភេទនេះកម្របរាជ័យក្នុងការសម្រេចគោល

ដៅនៃកម្ចី[14]របស់ខ្លួនណាស់។ អង្គការសន្សំម្លប់ព្រៃបានរកឃើញនៅក្នុងរបាយការណ៍ស្រាវជ្រាវរបស់ខ្លួនក្នុងឆ្នាំ ២០២២ មានចំណងជើងថា "បំណុលផ្ទាល់ខ្លួន និងគ្រួសារ[15]" ថាមានតែ៥% នៃអ្នកខ្ចីប៉ុណ្ណោះដែលមិនសម្រេចគោលបំណងដែលបានគ្រោងដើម្បីប្រើប្រាស់កម្ចីរបស់ខ្លួន (SMP, 2022) ។

## ៦.៣ អត្ថប្រយោជន៍ទៅវិញទៅមករវាងការចិញ្ចឹមជីវិតបែបជនបទ និងការអភិរក្ស

របាយការណ៍ស្តីពី "តួនាទីរបស់ព្រៃឈើពិភពលោក ឆ្នាំ២០១៨" របស់អង្គការស្បៀងនិងកសិកម្ម នៃសហប្រជាជាតិ (FAO, 2018) បានបង្ហាញនូវពន្លឺដ៏សំខាន់អំពីទំនាក់ទំនង ដែលមានស្រាប់រវាងព្រៃឈើ និងសក្តានុពលក្នុងការសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាពជាច្រើន មិនត្រឹមតែគោលដៅទី15[16]នៅក្នុងរបៀបវារៈការអភិវឌ្ឍប្រកបដោយចីរភាព (SDG[17]) នាឆ្នាំ2030។ ដែលបង្ករបរិយាកាសអំណោយផលដល់ អ្នកបង្កើតគោលនយោបាយនានា ដើម្បីបោះជំហាននៅលើតុល្យភាពដ៏ត្រឹមត្រូវមួយ នៅក្នុងការធ្វើសកម្មភាព ការវិនិយោគ និងភាពជាដៃគូផ្សេងៗ សំដៅឆ្ពោះទៅរកសុវត្ថិភាពស្បៀងអាហារ ការកាត់បន្ថយភាពក្រីក្រ ការ

[14] កម្ចីជាទូទៅត្រូវបានយកទៅទិញគ្រឿងយន្តកសិកម្ម ដី បង់ថ្លៃសាងសង់ បង់ថ្លៃព្យាបាល ទិញម៉ូតូ បើកតូបលក់ឥវ៉ាន់ ផ្តល់ថវិកាឱ្យគូស្វាមីភរិយាថ្មី ពង្រីកដី បង់ផ្តាច់បំណុលមុន។

[15] វិសាលភាពនៃការសិក្សានោះ គ្រប់ដណ្តប់ដែនជម្រកសត្វព្រៃព្រះរការផងដែរ ក្រៅពីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព។

[16] SDG15 ("Protect, restore and promote sustainable use of terrestrial ecosystems, sustainably manage forests, combat desertification, and halt and reverse land degradation and halt biodiversity loss".

[17] ហៅជាភាសាអង់គ្លេសថា Non-Timber Forest Products (NTFPs) ឬហៅថា Non-Wood Forest Products (NWFPs)

អភិរក្សប្រព័ន្ធជីវចម្រុះ និងជាចុងក្រោយស្វែងរកមាគ៌ាទៅកាន់ការអភិវឌ្ឍប្រកបដោយចីរភាព។

ដោយមើលឃើញនូវភាពសំខាន់មិនអាចកាត់ផ្តាច់បាន កម្ពុជាបានដាក់ចេញនូវទស្សនៈវិស័យគោលនយោបាយក្នុងអភិបាលកិច្ចធនធានព្រៃឈើជារួម ដោយរាប់បញ្ចូលទាំងការគ្រប់គ្រង ការប្រើប្រាស់ និងការអភិរក្សអនុផលព្រៃឈើ នៅក្នុងកម្មវិធីព្រៃឈើថ្នាក់ជាតិ (២០១០- ២០២៩) របស់ខ្លួន ដែលគាំទ្រដោយក្របខ័ណ្ឌគោលនយោបាយ និង គោលការណ៍ផ្លូវច្បាប់ពាក់ព័ន្ធជាមួយវិស័យព្រៃឈើ តំបន់ការពារ សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ និងដីធ្លី។ យ៉ាណាមិញ កម្មសិទ្ធិដី និងព្រៃឈើនៅក្នុងប្រទេសកម្ពុជា មានផលជះទៅលើសិទ្ធិនៅក្នុងការប្រើប្រាស់និងគ្រប់គ្រងធនធានព្រៃឈើ រួមទាំងអនុផលព្រៃឈើផងដែរ (MAFF, 2010)។

ការដកហូតអនុផលព្រៃឈើ[18] បានក្លាយទៅជាប្រធានបទស្នូលនៅក្នុងការគ្រប់គ្រង និងអភិរក្សធនធានព្រៃឈើ និងប្រព័ន្ធជីវចម្រុះប្រកបដោយនិរន្តភាពនៅទូទាំងពិភពលោក (FAO, 2018)។ ជាអកុសលរបាយការណ៍ជាផ្លូវការនៃបរិមាណផលិតកម្ម របស់អនុផលព្រៃឈើនៅរាយប៉ាយ មានកម្រិតតិចតួច និងមិនទាន់មានភាពច្បាស់លាស់ តែនេះក៏ដោយសារប្រព័ន្ធដំណើរការនេះមានភាពស្មុគស្មាញ និងមិនទាន់អាចមើលឃើញច្បាស់ ហើយការយល់ដឹងអំពី

[18] ហៅជាភាសាអង់គ្លេសថា Non-Timber Forest Products (NTFPs) ឬហៅថា Non-Wood Forest Products (NWFPs)

ចង្វាក់ផលិតកម្មរបស់វាក៏មិនទាន់គ្រប់គ្រាន់ (Jonathan P. et al, 2020)។ បើទោះបីជាមានភាពខ្វះទំនុកចិត្តអំពីសក្ដានុពលនៃការដកហូតអនុផលព្រៃឈើពីព្រៃធម្មជាតិ ក្នុងការចូលរួមអភិរក្សព្រៃនិងកាត់បន្ថយភាពក្រីក្របែបនេះក្តី ការដកហូតអនុផលព្រៃឈើដែលមានតម្រូវការទីផ្សារ និងអាចបំពេញគ្នាទៅវិញទៅមក ព្រមទាំងអាចច្របាច់បញ្ចូលគ្នាជាមួយការធ្វើស្រែចំការ គឺជាការផ្តល់នូវការចូលរួមដ៏សំខាន់សម្រាប់ជីវភាពនៅជនបទ (Mirjam A.F. Ros-Tonen, K. Freerk Wiersum, 2003) ។ ការអះអាងជាអន្តរជាតិនេះស៊ីចង្វាក់នឹងការសិក្សាមួយនៅក្នុងដែនជម្រកសត្វព្រៃភ្នំព្រិចប្រទេសកម្ពុជា ដែលបានរកឃើញថាយុទ្ធសាស្ត្រគ្រប់គ្រងអនុផលព្រៃឈើរបស់ប្រជាជន ទៅតាមកម្រិតនៃការធ្វើសមាហរណកម្មអនុផលព្រៃឈើទៅក្នុងប្រាក់ចំណូល កម្រិតនៃការរួមចំណែកពីអនុផលព្រៃឈើដល់ប្រាក់ចំណូលគ្រួសារ និងកម្រិតនៃការគ្រប់គ្រងអនុផលព្រៃឈើ ដោយមិនប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានប្រព័ន្ធជីវះចម្រុះ និងរចនាសម្ព័ន្ធព្រៃឈើ (Phanith C., 2022) ។ ការវិភាគទាំងនេះ ទំនងជាកំពុងឆ្លុះបញ្ចាំងផងដែរនូវតថភាពនៃការចិញ្ចឹមជីវិតបែបជនបទរបស់សហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិចកួយ នៅតំបន់ដែនជម្រកសត្វព្រៃព្រះរការ។ ដែលនេះអាចចាត់ទុកបានថាជាគម្រូនៃនិរន្តភាពជីវភាពបែបជនបទ ដែលផ្សារភ្ជាប់នឹងអនុផលព្រៃឈើថ្មីមួយទៀតនៅក្នុងប្រទេសកម្ពុជា។យ៉ាងណាមិញគម្រូជីវភាពនេះកំពុងរងការប៉ះពាល់ពីទំនាស់ដីធ្លីដែលអូសបន្លាយ និងការថយចុះជាលំដាប់នូវគម្របព្រៃឈើដូចដែលបានរកឃើញខាងលើ។

## ៦.៤ បញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ដែលជះឥទ្ធិពលដល់ការអភិរក្ស និងនិរន្តភាពនៃការចិញ្ចឹមជីវិតបែបជនបទ

យោងតាមការវិភាគនៅក្នុងរបាយការណ៍របស់អង្គការអិនធីអេហ្ភីអ៊ីភី (NTFPs-EP, 2020), ក្របខ័ណ្ឌគោលនយោបាយកម្ពុជា ពាក់ព័ន្ធនិងច្បាប់ព្រៃឈើ ច្បាប់តំបន់ការពារ សហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារ ទទួលស្គាល់យ៉ាងទូលំទូលាយនូវសិទ្ធិម្ចាស់កម្មសិទ្ធិ រាប់ចាប់ពីអ្នកកាន់សិទ្ធិរដ្ឋ សិទ្ធិប្រពៃណី និងកម្មសិទ្ធិករផ្សេងៗ ដែលមានភាពខុសៗគ្នា (បុគ្គលខុសពីសមូហភាព សហគមន៍មូលដ្ឋានខុសពីសហគមន៍ជនជាតិដើមភាគតិច។) ច្បាប់ទាំងនេះមានភាពច្បាស់លាស់ចំពោះការមិនរឹតត្បិតនិងការជ្រៀតជ្រែកពីរដ្ឋនិងគម្រោងសម្បទានផ្សេងៗ ទៅលើការប្រើប្រាស់សិទ្ធិលក្ខណៈប្រពៃណី។ ក្របខ័ណ្ឌគោលនយោបាយទាំងនេះផ្តល់នូវឱកាសជាច្រើនសម្រាប់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានក្នុងការធានានូវសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់ខ្លួនលើដីធ្លី។ ទោះជាយ៉ាងនេះក្តី អត្ថន័យក្នុងការអនុវត្តជាក់ស្តែងរបស់អ្នកប្រើប្រាស់សិទ្ធិជាប្រពៃណី និងការអាស្រ័យផលអនុផលព្រៃឈើនៅមិនទាន់កំណត់ច្បាស់លាស់។

គួសបញ្ជាក់ផងដែរថា ភាពស្មុគស្មាញនៅក្នុងដំណើរការរដ្ឋបាលដើម្បីបង្កើតសហគមន៍តំបន់ការពារធម្មជាតិ (CPA) បានបង្ខំឱ្យសហគមន៍ពឹងផ្អែកលើមន្ត្រីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ឱ្យជួយនៅគ្រប់ដំណាក់កាល ដូច្នេះនៅពេលមានទំនាស់កើតឡើងជាពិសេសទាក់ទងនិងដីធ្លី CPA ឋិតនៅក្នុងស្ថានភាពទន់ខ្សោយក្នុងការប្រឈមមុខជាមួយគូបដិបក្ស ដែល

ភាគច្រើនមកពីខាងក្រៅសហគមន៍ ហើយដែលជាធម្មតាមានអភ័យឯកសិទ្ធិផ្លូវការ ឬឯកសារផ្លូវច្បាប់ (ប័ណ្ណកម្មសិទ្ធិដីធ្លី កិច្ចសន្យាសម្បទាន និងបញ្ជាក់សិទ្ធិកាន់កាប់ផ្សេងៗ) ដើម្បីគាំទ្រការទាមទាររបស់ពួកគេ នៅក្នុងទំនាស់នោះ។ បើទោះបីជាទំនាស់បែបនេះបានអូសបន្លាយក្តី យន្តការនិងសេចក្តីណែនាំក្នុងការដោះស្រាយទំនាស់នៅតែមានភាពមិនច្បាស់លាស់ (CEDT & ClientEarth, 2022)។

ជាមួយគ្នានេះដែរ ផលប្រយោជន៍សេដ្ឋកិច្ចពេញលេញ ពីសហគមន៍ព្រៃឈើមានភាពវែងអន្លាយនិងស្មុគស្មាញ ហើយសិទ្ធិក៏ត្រូវបានរឹតត្បិត។ វាមានសភាពដូចគ្នាសម្រាប់ការអនុវត្តនៅក្នុងតំបន់ការពារធម្មជាតិ។ លើសពីនេះទៅទៀត គោលនយោបាយដែលមានស្រាប់ពាក់ព័ន្ធនិងសិទ្ធិទទួលបានអនុផលព្រៃឈើរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ទំនងជាតម្រង់ឆ្ពោះទៅរកភាពជោគជ័យរបស់សម្បទានព្រៃឈើបែបឧស្សាហកម្មឯកជន ជាជាងផ្តល់ការគាំទ្រដល់ការផ្តួចផ្តើមសហគ្រិនភាពបែបសហគមន៍មូលដ្ឋាន (NTFPs-EP, 2020)។ កត្តានេះបានក្លាយជាឧបសគ្គ[19]នៅក្នុងដំណើរនៃការធ្វើអន្តរកាល ផ្នែកជីវភាពគ្រួសារ ដោយខ្លួនឯងរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដើម្បីចាក់ចេញពីការពឹងផ្អែកទាំងស្រុងលើការធ្វើស្រែចំការ ហើយដែលនៅក្នុងអន្តរកាលនេះ ចំណូលតាមរដូវ រកបានពីអនុផលព្រៃឈើតើតួនាទីសំខាន់ក្នុងការទប់ទល់

[19] ពាក្យនេះត្រូវបានហៅជាភាសាអង់គ្លេសថា "Transition of Family's Livelihoods" ។ វាជាដំណើរចាកចេញពីការពឹងផ្អែកតែលើការធ្វើស្រែចំការ (On-farm) មួយមុខ ហើយឈានទៅចាប់យករបរដែលក្រៅពីការស្រែចំការ (Off-farm)។

ចំណាយ ព្រមទាំងការសងបំណុល ឬកម្ចីពីមីក្រូហិរញ្ញវត្ថុ ដែលយកមកពង្រីកឬបង្កើតមុខរបរ (Sansam Mlup Prey, 2022)។ សហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិច ចូលរួមក្នុងការការពារព្រៃឈើដោយគ្មានល័ក្ខខ័ណ្ឌ ដោយហេតុថាអនុផលព្រៃឈើដែលជាប្រភពចំណូលបំពេញបន្ថែមសំខាន់របស់គាត់ អាស្រ័យលើភាពបិតបេរនៃព្រៃឈើទាំងមូល។

## ៧. ការពិភាក្សាលទ្ធផលស្រាវជ្រាវ

### ៧.១ ការបាត់បង់គម្របព្រៃឈើ និងការចូលរួមការពារព្រៃឈើ

ការថយចុះគម្របព្រៃឈើគួរឱ្យព្រួយបារម្ភ ដូចបានរកឃើញ ជាពិសេសនៅតំបន់ដែនជម្រកសត្វព្រៃព្រះរការ។ នេះជាហេតុបណ្ដាលឱ្យលេចឡើងនូវចលនាការពារព្រៃឈើ និងការយកចិត្តទុកដាក់កាន់តែច្រើនឡើងចំពោះសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចនៅតំបន់នោះ ជាពិសេសតាមរយៈការចូលរួមល្បាតព្រៃ ដើម្បីបង្ហាញពីសកម្មភាពកាប់ឈើខុសច្បាប់ (CamboJA, 2025), (Mongabay, 2023)។ នេះគឺជាករណីសិក្សាមួយដែលឆ្លុះបញ្ចាំងពីទិដ្ឋភាពទូលាយជាងនេះ ជាក់ស្តែង ស្ថានភាពនៃការថយចុះគម្របព្រៃឈើ មិនត្រឹមតែមាននៅក្នុងដែនជម្រកសត្វព្រៃព្រះរការប៉ុណ្ណោះទេ វាកើតឡើងផងដែរនៅតំបន់ការពារធម្មជាតិនៅជាប់គ្នានោះ តួយ៉ាងដែនជម្រកសត្វព្រៃព្រៃឡង់ និងព្រៃសង្ឃសហគមន៍រុក្ខាវ័ន្ត (CEEJA, 2023)។

ដោយសារផលប្រយោជន៍សម្រាប់ការចិញ្ចឹមជីវិត បើទោះបីជាមានការរឹតត្បិតសិទ្ធិសេរីភាពក្នុងការចូលរួមការពារ (ល្បាត) ព្រៃពីមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ ទទួលរងការបញ្ចុះ

បញ្ចូល បំភិតបំភ័យពីឈ្មួញជួញដូរឈើ បណ្តាញការពារព្រៃព្រះរការ រួមជាមួយបណ្តាញផ្សេងៗទៀត(នៅតំបន់ដែនជម្រកសត្វព្រៃក្បៀរនោះ) នៅតែបន្តសហការគ្នាចូលរួមយ៉ាងសស្រាក់សស្រាំ និងមានភាពច្នៃប្រឌិតក្នុងការការពារព្រៃដែលដឹកនាំដោយសមាជិកសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចកួយ។ ក្នុងនោះមានបណ្តាញសហគមន៍ព្រៃព្រះរការ (PFCN) បង្កើតឡើងក្នុងឆ្នាំ២០១៣ (ដំណាលគ្នានិងបណ្តាញសហគមន៍ព្រៃឡង់ ព្រៃរុក្ខវ័ន្ត) ដែលមានសហគមន៍មកពីភូមិចំនួន២២។ យើងក៏សង្កេតឃើញមានការចែករំលែកព័ត៌មានទាន់ហេតុការណ៍ ដ៏សកម្ម អំពីបទល្មើសព្រៃឈើ ការល្បាតព្រៃ និងបញ្ហាដីធ្លីតាមប្រព័ន្ធសង្គមបណ្តាញហ្វេសប៊ុក (Facebook) របស់សហគមន៍ជនជាតិដើមភាគតិចកួយប្រមេរុ ដែលមានអ្នកតាមដានជាង២ពាន់ (2K) នាក់។

ការបាត់បង់ព្រៃឈើច្រើនជាងគេ ប្រមាណ៨៥%នៃការបាត់បង់សរុប ៤, ៨៤៩ ហិកតា កើតឡើងចាប់ពីឆ្នាំ២០១៦មក នៅពេលដែលតំបន់ព្រៃព្រះរការចាប់ផ្តើមក្លាយទៅជាតំបន់ដែនជម្រកសត្វព្រៃ។ នេះអាចអះអាងបានថា ការការពារដែនជម្រកសត្វព្រៃព្រះរការដោយស្ថាប័នទទួលខុសត្រូវផ្ទាល់ គឺមិនមានប្រសិទ្ធភាពឡើយ។ តួយ៉ាងការបន្តបាត់បង់ដើមជ័រច្បោះ (ដើមឈើទាលនិងដើមត្រាច) ដែលមួយភាគធំបណ្តាលមកពីការកាប់ដើមលក់ ពីឈ្មួញខាងក្រៅ តាមរយៈការទិញពីម្ចាស់ដើមច្បោះក្នុងរូបភាពបញ្ចុះបញ្ចូលនិងបំភិតបំភ័យ។ ម្ចាស់ដើមច្បោះមួយចំនួន រងសម្ពាធពីអ្នកខាងក្រៅ បង្ខំឱ្យលក់ដើមច្បោះឱ្យគេ (ជាទូទៅគេម៉ៅដើម រួមកាប់លក់)។ យ៉ាង

ណាមិញ សម្រាប់សកម្មជនជនជាតិដើមភាគតិចនៅក្នុងបណ្ដាញការពារព្រៃព្រះរការជាច្រើន បានប្រែក្លាយការភ័យខ្លាចនេះទៅជាកម្លាំងក្នុងការខិតខំចូលរួមការពារ (ល្បាត) ព្រៃទៅវិញ។ ដោយសារមានការយល់ដឹងសិទ្ធិនិងច្បាប់កាន់តែច្រើន សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចបាន បង្កើតបណ្ដាញដើម្បីការពារធម្មជាតិដោយខ្លួនឯង។ ការរើសអើងដែលនាំឱ្យបាត់បង់កម្លាំងសាមគ្គីភាពក្នុងការទប់ស្កាត់បទល្មើសព្រៃឈើ។

ស្របពេលដែល អនុផលព្រៃឈើដែលជាប្រភពចំណូលតាមរដូវរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច កំពុងរងការគំរាមកំហែងដោយការកាប់បំផ្លាញព្រៃឈើ ទំនាស់ដីធ្លីដ៏អូសបន្លាយ នៅតែជាឧបសគ្គរារាំងស្ថេរភាពនៃការផលិតស្បៀងអាហាររបស់ពួកគាត់។ បន្ទាប់ការផ្អាកដំណើរការក្រុមហ៊ុនស្ករអំពៅ មិនទាន់ឃើញមានចំណាត់ការជាក់លាក់ទៅលើដីសម្បទានសេដ្ឋកិច្ចដែលបានផ្ដល់ឱ្យក្រុមហ៊ុនចិនទាំងអស់នោះ។ នេះហាក់បង្ហាញថាអ្នកធ្វើនិងអនុវត្តន៍គោលនយោបាយពាក់ព័ន្ធរបស់កម្ពុជា មិនបានរៀនសូត្រពីមេរៀននៃការបាត់បង់ព្រៃឈើដ៏គំហុកឡើយ ដែលភាគច្រើន ត្រូវបានរកឃើញថា បណ្ដាលមកពីការឈូសឆាយក្រោមរូបភាពដីសម្បទានសេដ្ឋកិច្ច (Hansen et al.,2013) មានទំហំធំ និងរយៈពេលយូរ ហើយមួយភាគធំអនុវត្តន៍នៅក្នុងតំបន់ដីព្រៃសំខាន់ៗ រួមទាំងតំបន់ការពារធម្មជាតិផងដែរ។ អ្នកភូមិដែលត្រូវបានសម្ភាសន៍ អះអាងដូចៗគ្នាអំពីការរឹតត្បិតសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន រួមទាំងជនជាតិដើមភាគតិចកួយនៅទីនេះ ក្នុងការប្រើប្រាស់ដីធ្លីក្នុងការធ្វើស្រែចំការ នៅក្នុង

ឬជាប់ដែនជម្រកសត្វព្រៃ បើទោះបីជាដីនោះធ្លាប់ជាកន្លែងពួកគាត់ធ្លាប់បង្ករបង្កើនផលដំណាំក៏ដោយចុះ។ ការអនុវត្តច្បាប់ដែលមិនស្មើភាពគ្នា ដោយសូម្បីតែប្រជាពលរដ្ឋមូលដ្ឋានក៏មិនមានសិទ្ធិកាប់ឆ្ការដោយចបកាំបិត ប៉ុន្តែអ្នកមានបុណ្យស័ក្តិធំៗ គេមានសិទ្ធិ (អំណាច) ឈូសឆាយដីព្រៃរាបដល់ដី ពុំមានមន្ត្រីបរិស្ថានណា (ឧទ្យានុរក្ស) មកទប់ស្កាត់។

## ៧.២ ការមើលរំលងកិច្ចខិតខំប្រឹងប្រែងអភិរក្សរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច

បើទោះបីជាកិច្ចខិតខំប្រឹងប្រែងដ៏សំខាន់ និងគ្រោះថ្នាក់នេះ មិនត្រូវបានទទួលស្គាល់ដោយអាជ្ញាធរ ឬស្ថានប័នរដ្ឋមួយចំនួនក៏ដោយ តែយើងមើលឃើញថាជាសហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិច នៅតែបន្តខិតខំប្រឹងប្រែង រកវិធីសាស្ត្រ ដើម្បីចូលរួមក្នុងកិច្ចការពារធនធានព្រៃឈើ។ កត្តានេះបានញ៉ាំងឱ្យមានការរើបំរះ តាមរយៈសកម្មភាពផ្សេងៗ ជាពិសេសការចែករំលែកការពិតតាមប្រព័ន្ធបណ្តាញសង្គម ដូចជាហ្វេសប៊ុក (Facebook) របស់សហគមន៍ជនជាតិដើមភាគតិចកួយប្រមេរុ ដែលមានអ្នកចូលមើលជាង២ពាន់ (2K) នាក់ៗនិងមានសារព័ត៌មានមួយចំនួនបានលើកយកមកផ្សព្វផ្សាយផងដែរ។

កាន់តែញឹកញាប់ប់ទៅ បទល្មើសជាក់ស្តែងដែលរកឃើញដោយបណ្តាញសហគមន៍ និងអ្នកស្ម័គ្រចិត្តទាំងនេះ ត្រូវបានទាត់ចោល ជាពិសេសដោយមន្ត្រីឧទ្យានុរក្សដែលការចូលរួមល្បាតព្រៃដោយស្ម័គ្រចិត្តនេះ ត្រូវបានទទួលរងការចោទប្រកាន់ថាជាសកម្មភាពមិនស្របច្បាប់។ នេះជាទម្រង់នៃការរើសអើងមួយ ដែលអាចកើតឡើងដោយចេតនាឬ

អចេតនាពីមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធជាពិសេសក្រសួងបរិស្ថាន និងធនធានធម្មជាតិ ការរើសអើងនេះទំនងជាទាក់ទងខ្លាំងជាមួយប្រសិទ្ធភាពនៃការបែងចែកតំបន់ការពារធម្មជាតិ (ដែលមានតំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍) និងការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ (CPA) ដែលជាទូទៅការចូលរួមរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចត្រូវបានមើលរំលង ឬធ្វើមិនបានគ្រប់ជ្រុងជ្រោយ (ClientEarth & CEDT, 2022)។ នៅក្នុងការពិភាក្សាជាក្រុមរវាងសមាជិក CPA និងសហគមន៍ជនជាតិដើមភាគតិចក្ដួយទូទៅ (និងមួយចំនួនជាសមាជិក PFCN) ពួកគាត់បានបង្ហាញពីការខ្វះជំនឿលើប្រសិទ្ធភាពនៃការបំពេញការងារការពារធម្មជាតិ ឬការល្បាតព្រៃនៅក្នុងព្រំដែន CPA ស្របពេលដែលសមាជិក CPA ខ្លួនឯង ក៏មានភាពស្រពេចស្រពិលនឹងតួនាទីរបស់ខ្លួនផងដែរ។ ប្រហែលដោយសារភាពស្រពេចស្រពិលនេះហើយ ដែលញ៉ាំងឱ្យសមាជិក CPA មួយចំនួន ឆ្លៀតចូលរួមជាមួយបណ្ដាញសហគមន៍ស្ម័គ្រចិត្ត PFCN ដើម្បីល្បាតព្រៃបន្ថែម ដែលគាត់អាចល្បាតមិនត្រឹមតែនៅក្នុងព្រំដែនសហគមន៍តំបន់ការពារធម្មជាតិ តំបន់ប្រើប្រាស់ដោយចីរភាពប៉ុណ្ណោះទេ ប៉ុន្តែពេលខ្លះក៏ល្បាតនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្សផងដែរ (ប៉ុន្តែសកម្មភាពនេះកាន់តែលំបាកទៅៗដោយសារការបំភិតបំភ័យថាខុសច្បាប់តំបន់ការពារក្នុងឆ្នាំ២០១៦) ដែលបទល្មើសព្រៃឈើត្រូវបានរកឃើញដោយក្រុមល្បាត PFCNនេះថានៅតែបន្តកើតឡើង។ គួសបញ្ជាក់ផងដែរថា CPA អាចបង្កើតឡើង និងដើរល្បាតបានតែនៅក្នុងតំបន់

ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ប៉ុណ្ណោះ ហើយ មិនគ្រប់តំបន់ការពារធម្មជាតិសុទ្ធតែមាន CPA ឡើយ។

សមាជិកសហគមន៍ជនជាតិដើមភាគតិចកួយ ដែលធ្លាប់បានចូលរួមល្បាតបទល្មើសព្រៃឈើ នៅដែនជម្រកសត្វព្រៃព្រះរការ បានរៀបរាប់នៅក្នុងបទសម្ភាសន៍ថា ពេលខ្លះ ពួកគាត់ជួបបទល្មើសព្រៃឈើ ហើយពួកគាត់បានជូនដំណឹងទៅមន្ទីបរិស្ថាន (ឧទ្យានុរក្ស) ប៉ុន្តែមន្ត្រីបរិស្ថានមិនបានបង្ហាញខ្លួនទាន់ពេលវេលាឡើយ ដោយមន្ត្រីរូបនោះប្រាប់ថាការធ្វើដំណើរមានការលំបាក ហើយគាត់មានគ្នាតិច មិនអាចចល័តបានលឿន និងសព្វទីកន្លែងឡើយ។ ករណីនេះ បានបង្ហាញថាបណ្តាញសហគមន៍ PFCN កំពុងមានតួនាទីយ៉ាងសំខាន់នៅក្នុងការបំពេញចន្លោះខ្វះខាតរបស់ឧទ្យានុរក្ស។ បើទោះបីជាបែបនេះក្តី កន្លងមកការល្បាតដោយបណ្តាញសហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិច នៅតែត្រូវបានក្រសួងបរិស្ថានទាមទារឱ្យមានការចុះបញ្ជី ទើបអាចការពារព្រៃដោយស្របច្បាប់ បើមិនដូច្នោះទេ ក្រសួងចាត់ទុកជាសកម្មភាពខុសច្បាប់ស្តីអំពីច្បាប់តំបន់ការពារធម្មជាតិ។ នេះអាចចាត់ទុកបានថាជាការបកស្រាយច្បាប់មានលក្ខណះចង្អៀតចង្អល់ និងបង្អាក់ទឹកចិត្តដល់សហគមន៍ និងសាធារណជនដែលស្រលាញ់បរិស្ថាន និងចង់ចូលរួមការការពារធនធានធម្មជាតិ។ សិទ្ធិសេរីភាពរបស់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងសាធារណជន ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់ពាក់ព័ន្ធផ្សេងៗ ជាពិសេស ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ត្រង់មាត្រា៤ គូសបញ្ជាក់យ៉ាងថា ការគ្រប់គ្រង តំបន់

ការពារធម្មជាតិត្រូវធានានូវសិទ្ធិរបស់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងសាធារណជនដើម្បីចូលរួមធ្វើការសម្រេចចិត្តលើការគ្រប់គ្រង និងការអភិរក្សជីវៈចម្រុះប្រកបដោយនិរន្តភាព។ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ មាត្រា១ ក៏បានចង្អុលបង្ហាញពីការលើកទឹកចិត្តនិងផ្តល់លទ្ធភាពឱ្យសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ។ ដូច្នេះក្រុមសិក្សាស្រាវជ្រាវចាត់ទុកថាវាជាការខាតបង់កម្លាំងក្នុងការចូលរួមការពារធម្មជាតិ ជាពិសេសពីសំណាក់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចដែលគាត់បានទទួលអត្ថប្រយោជន៍ពីធម្មជាតិ (អនុផលព្រៃឈើ) ហើយគ្រាន់តែចង់ផ្តល់ត្រឡប់ទៅវិញតាមរយៈកម្លាំងចូលរួមល្បាតព្រៃ។

## ៧.៣ និរន្តភាពនៃការចិញ្ចឹមជីវិតបែបជនបទរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច

ក្រៅពីកត្តាគំរាមកំហែងដោយការថយចុះព្រៃឈើ និងវិបត្តិដីធ្លី ការចិញ្ចឹមជីវិតបែបជនបទរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាននៅតែមានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួតជាមួយកិច្ចខិតខំប្រឹងប្រែងអភិរក្សជាពិសេសនៅក្នុងតំបន់ព្រៃព្រះរការដែលអាចចាត់ទុកថាជាគម្រូភាពមួយនៃនិរន្តភាពនៃការចិញ្ចឹមជិវិតនៅជនបទ ដោយសារវាត្រូវបានរកឃើញថាមានល័ក្ខខ័ណ្ឌសមស្រប នៅក្នុងក្របខ័ណ្ឌគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាពនានា (SDGs) ជាពិសេស SDG1, SDG13, និង SDG15។ ក្រុមសិក្សាបានធ្វើការឆ្លុះបញ្ចាំងស្ថានភាពជីវភាពរបស់ជនជាតិដើមភាគតិចកួយ និងសហគមន៍មូល

ដ្ឋាន ជាពិសេសដែលមានភ្ជាប់ជាមួយ ការធ្វើស្រែរួម ការបង្កាត់ពូជស្រូវ និង សកម្មភាពសហគមន៍រួមនានា ថាមាន ចរិតលក្ខណៈនៃនិរន្តភាពជីវភាព[20] របស់អង្គការ ស្បៀងអាហារ និង កសិកម្ម នៃអង្គការសហប្រជាជាតិ (FAO)។ នៅពេលពួកគាត់ចេះធ្វើការ សហការគ្នាឆ្ពោះទៅរកគោលដៅរួម តាមរយៈការចែករំលែកចំណេះដឹង (ធនធានមនុស្ស[21] ធនធានហិរញ្ញវត្ថុ[22] និងធនធានរូបសាស្ត្រ[23] អាចជាដីស្រែ អនុផលព្រៃឈើ ក្រុមសន្សំ) ការគាំទ្រ ដល់ប្រព័ន្ធសហគមន៍រួមឬផល ប្រយោជន៍សមូលហភាព (ធនធាន សង្គម[24])។

ភាពរឹងមាំផ្នែកជីវភាព ដែល មានសាមគ្គីភាព និងគោលដៅរួមនេះ ក៏បានអនុញ្ញាតឱ្យពួកគាត់មើលឃើញ និងចូលរួមគិតគូរអំពីហានិភ័យរួមជា ពិសេស ការបាត់បង់ព្រៃឈើ និង ទំនាស់ដីធ្លីជាប្រព័ន្ធ ដែលកំពុងបន្តកើត ឡើង។ ជាក់ស្តែងពួកគាត់បានចូលរួម យ៉ាងសកម្មភាព និងផុសផុលក្នុងការត ស៊ូមតិ តទល់នឹងអយុត្តិធម៌ដីធ្លីជាមួយ ក្រុមហ៊ុនស្ករអំពៅចិន និងការចូលរួម ល្បាតព្រៃ បើទោះបីនៅក្រៅ ក្របខ័ណ្ឌសហគមន៍តំបន់ការពារធម្ម ជាតិ (CPA) ហើយរងការរឹតត្បិតសិទ្ធិ សេរីភាព និងចោទប្រកាន់យ៉ាងណាក៏ ដោយចុះ។ ដូច្នេះពិនិត្យមើលឃើញថា ភាពរឹងមាំឬភាពធន់នៃជីវភាពជនបទ មិនត្រឹមតែចាំបាច់សម្រាប់ការកាត់ បន្ថយភាពក្រីក្ររបស់ពួកគាត់ប៉ុណ្ណោះ ទេ (SDG1: គ្មានភាពក្រីក្រ) ប៉ុន្តែវាក៏ ដើរតួនាទីសំខាន់នៅក្នុងការអភិរក្សប រិស្ថានធម្មជាតិ (SDG15: ជីវិតលើដី)

[20] Characteristics of Sustainable Livelihood
[21] Human Capital
[22] Financial Capital
[23] Physical Capital
[24] Social Capital

និងភាពធន់នឹងអាកាសធាតុ (SDG13: សកម្មភាពអាកាសធាតុ)។ តាមរយៈការលើកស្ទួយនិរន្តរភាពនៃការចិញ្ចឹមជីវិតជនបទ យើងអាចសម្រេចបានដំណោះស្រាយឈ្នះៗ ទាំងការអាចធ្វើឱ្យប្រសើរឡើងនូវសុខមាលភាពមនុស្ស និងស្របពេលជាមួយគ្នាអាចការពារនូវធនធានធម្មជាតិរបស់ភពផែនដី។

## ៨. សេចក្តីសន្និដ្ឋាន

ផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងការពិភាក្សាលទ្ធផលខាងលើនេះ យើងអាចសន្និដ្ឋានបានថាសហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិចក្កួយ មានភាពធន់ផ្នែកសេដ្ឋកិច្ចមូលដ្ឋាន ដោយសារធនធានធម្មជាតិជាពិសេសអនុផលព្រៃឈើ (ដែលមានទីផ្សារ និងសក្តានុពលអាជីវកម្ម) នៅមានច្រើន ហើយពួកគាត់ចូលរួមក្នុងការអភិរក្សធនធានទាំងនេះដោយស្ម័គ្រចិត្ត បើទោះបីជាមានការរឹតត្បិតសិទ្ធិសេរីភាព និងការគំរាមកំហែងក្តី។ កត្តានេះបានគូសបញ្ជាក់កាន់តែច្បាស់នូវអត្ថប្រយោជន៍ទៅវិញទៅមករវាងកត្តាជីវភាព និងកិច្ចខិតខំប្រឹងប្រែងចូលរួមក្នុងការអភិរក្សរបស់គាត់នៅក្នុងតំបន់ដែនជម្រកសត្វព្រៃព្រះរការ។

យ៉ាងណាមិញ សក្តានុពលនៃទំនាក់ទំនងបែបធម្មជាតិដែលមានស្រាប់នេះ ត្រូវបានមើលរំលងដោយអ្នកអនុវត្តច្បាប់ និងមិនសូវទទួលបានការរាប់បញ្ចូលដិតដល់ពីគម្រោងឬកម្មវិធីអភិវឌ្ឍ និងអភិរក្ស។ ជាក់ស្តែង ជំនួសឱ្យការផ្តល់ការគាំទ្រ និងលើកទឹកចិត្ត សកម្មភាពចូលរួមឃ្លាំមើលបទល្មើសព្រៃឈើរបស់បណ្តាញការពារព្រៃព្រះរការ (PFCN) ត្រូវបានរឹតត្បិត។ រដ្ឋផ្តល់អាទិភាពច្រើនដល់គម្រោងអភិវឌ្ឍខ្នាតធំដូចជាសម្បទានដីសេដ្ឋ

កិច្ច បើទោះបីត្រូវអនុវត្តនៅលើដីស្រែចំការដែលជាឆ្អាំងបាយចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចក្ដីយក៏ដោយ។ រីឯគម្រោងអភិរក្ស បើទោះបីជាមានការគិតគូរដល់ការលើកស្ទួយជីវភាពសហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិច ប៉ុន្តែការផ្សារភ្ជាប់ជាមួយសហគមន៍មូលដ្ឋានមានលក្ខណៈតូចចង្អៀត ដោយសារការអនុវត្តសកម្មភាពអភិរក្សប្រព្រឹត្តទៅតែជាមួយ CPA ស្របពេលដែលការការពារធនធានធម្មជាតិ (ជាពិសេសព្រៃឈើ) របស់ CPA ត្រូវបានប្រជាពលរដ្ឋមូលដ្ឋានចាត់ទុកថាមិនមានប្រសិទ្ធភាព។ ការមើលរំលងនេះ បណ្ដាលឱ្យមានផលប៉ះពាល់ជាអវិជ្ជមានគួរឱ្យព្រួយបារម្ភ ផលប៉ះពាល់នោះ រាប់តាំងពីកត្តាសង្គម សេដ្ឋកិច្ចនយោបាយ រហូតដល់បរិស្ថានផងដែរ។ ការខាតបង់កម្លាំងប្រជាពលរដ្ឋមូលដ្ឋាន អង្គការសង្គមស៊ីវិល និងមហាជនក្នុងការចូលរួមល្បាតព្រៃ រហូតដល់ការបែកបាក់សាមគ្គីជាតិ រវាងរាស្ត្រនិងរដ្ឋ។

សហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិចក្ដីយ ប្រមូលផលអនុផលព្រៃឈើ ដែលមានសក្ដានុពលអាជីវកម្ម ដើម្បីលក់ឱ្យឈ្មួញកណ្ដាលរកចំណូលតាមរដូវប៉ុណ្ណោះ។ ចំណែកការភ្ជាប់ទៅក្នុងការកែច្នៃ ឬសហគ្រិនភាពដែលអាចកែច្នៃទៅជាទំនិញមានតម្លៃខ្ពស់ក្នុងទីផ្សារ នៅមានកម្រិតនៅឡើយ។

## ៩. ការផ្ដល់អនុសាសន៍

ផ្អែកលើលទ្ធផលស្រាវជ្រាវ និងការពិភាក្សាលទ្ធផលខាងលើ អនុសាសន៍ខាងក្រោមមានបំណង ពង្រឹងនិរន្តភាពនៃការចិញ្ចឹមជីវិតតាមជនបទ និងកិច្ចខំប្រឹងប្រែងអភិរក្សតំបន់ដែន

ជម្រកសត្វព្រៃព្រះរការ។ សកម្មភាពទាំងនេះស្នើឡើងដើម្បីដោះស្រាយបញ្ហាប្រឈមធ្ងន់ធ្ងរនានា ដូចជាការបាត់បង់ព្រៃឈើ ទំនាស់ដីធ្លី និងសក្ដានុពលសហគ្រិនភាពសហគមន៍ និងសង្គម ដែលមិនទាន់បានអភិវឌ្ឍដិតដល់។ អនុសាសន៍នីមួយៗ បង្កើតឡើងដើម្បីធ្វើឱ្យប្រសើរឡើងគោលនយោបាយ ការផ្សារភ្ជាប់ជាមួយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច និងធ្វើឱ្យស៊ីសង្វាក់ជាមួយគោលដៅអភិវឌ្ឍប្រកបដោយចីរភាពជាគន្លឹះមួយចំនួន ក្នុងការធានាស្ថេរភាពប្រព័ន្ធអេកូឡូស៊ីនិងសេដ្ឋកិច្ចរយៈពេលវែង ដូចមានរៀបរាប់ខាងក្រោម។

ដើម្បីធានានិរន្តភាពនៃការចិញ្ចឹមជីវិតបែបជនបទ និងការអភិរក្សនៅក្នុងដែនជម្រកសត្វព្រៃព្រះរការ វិធីសាស្ត្រនៃគម្រោងអភិវឌ្ឍ និងអភិរក្សដែលកំពុងប្រព្រឹត្តទៅ ត្រូវតែឆ្លងកាត់ការធ្វើការផ្ទុះបញ្ចាំងឱ្យបានទៀងទាត់ និងធ្វើឡើងជាលក្ខណៈប្រព័ន្ធ។ ដំណើរការនេះ គួររួមបញ្ចូលទំនាក់ទំនងជាចលករវវាងជីវភាព និងកិច្ចខិតខំប្រឹងប្រែងអភិរក្ស ដូចដែលបានកំណត់នៅក្នុងការសិក្សានេះ ដែលវាស៊ីសង្វាក់ជាមួយនឹងគោលនយោបាយអភិវឌ្ឍផ្សេងៗ រួមទាំង SDGs ផងដែរ។ ក្នុងនោះមាន SDG1: គ្មានភាពក្រីក្រ, SDG13: សកម្មភាពអាកាសធាតុ, SDG15: ជីវិតនៅលើដី។

ការដោះស្រាយវិបត្តិព្រៃឈើត្រូវតែធ្វើឡើងស្របពេលជាមួយគ្នា និងវិបត្តិដីធ្លី ជាពិសេសរវាងអ្នកពាក់ព័ន្ធនិងក្រុមហ៊ុនស្កររអំពៅចិន ជាមួយនិងសហគមន៍រងផលប៉ះពាល់។ ដោយសារបញ្ហាទាំងពីរនេះមានទំនាក់ទំនងគ្នាជិតស្និត ការដោះស្រាយដែលធ្វើឡើងទន្ទឹមគ្នា នឹងធានាដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និង

និរន្តភាព ក្នុងការការពារទាំងបរិស្ថាន និងជីវភាពសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។

បន្ថែមពីលើនេះ វាជាការចាំបាច់ដើម្បីកាត់បន្ថយឬលុបបំបាត់ឧបសគ្គផ្នែករដ្ឋបាលបែបការិយាល័យធិបតេយ្យ ដែលបង្អាក់ការចូលរួមរបស់បណ្ដាញសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច សង្គមស៊ីវិល និងសាធារណជនទូទៅ នៅក្នុងកិច្ចខិតខំប្រឹងប្រែងការពារព្រៃឈើ។ ការកែតម្រូវឡើងវិញនូវដំណើរការនេះ អាចបង្កើតបានជាបរិយាកាសអំណោយផល លើកទឹកចិត្តឱ្យមានការចូលរួមកាន់តែច្រើនឡើង នៅក្នុងការល្បាតព្រៃ និងការផ្ដួចផ្ដើមក្នុងការអភិរក្សដែលប្រកបដោយបរិយាបន្ន។

ដើម្បីធ្វើឱ្យប្រសើរឡើងនូវការសម្រេចចិត្តប្រកបដោយបរិយាបន្ន តំណាងសហគមន៍ ឬជនបង្គោលសហគមន៍ ត្រូវតែមានភាពជាតំណាងពិតប្រាកដ (ដែលមិនត្រឹមតែតាមរយៈខ្សែបណ្ដាញរដ្ឋបាលគ្រប់គ្រងភូមិឃុំ ឬចាស់ទុំប្រពៃណីមូលដ្ឋាន និងជនជាតិដើមភាគតិចប៉ុណ្ណោះទេ) ដើម្បីអាចឆ្លុះបញ្ចាំងទស្សនៈសមាជិកសហគមន៍ភាគច្រើន ដោយពិតប្រាកដ។ វាជាការសំខាន់ក្នុងការជៀសវាងការបកស្រាយច្បាប់ដោយមានភាពលម្អៀង ឬបកស្រាយមិនត្រឹមត្រូវ ដើម្បីប្រឆាំងពួកគាត់។ ភាពច្នៃប្រឌិតនៅក្នុងដំណើរការនៃការកៀរគរសមាជិក បណ្ដាញមូលដ្ឋាន និងជនជាតិដើមភាគតិចឱ្យបានកាន់តែច្រើន គួរតែត្រូវបានលើកទឹកចិត្ត ដើម្បីកិច្ចខិតខំប្រឹងប្រែងអភិរក្សដែលមានការចូលរួមទូលំទូលាយ។

ជាចុងក្រោយ វាជាតម្រូវការចាំបាច់ក្នុងការផ្ដល់ការគាំទ្រប្រកបដោយអត្ថន័យ និងបរិយាបន្ន ដល់សហគ្រាស សហគមន៍ ឬសង្គម

ជាពិសេសនៅក្នុងការកែច្នៃអនុផល ព្រៃឈើ។ នេះរួមទាំងជំនួយបច្ចេកទេស សម្រាប់ការកែច្នៃអនុផលព្រៃឈើនិងការបណ្តុះបណ្តាលការវិភាគប្រព័ន្ធសេដ្ឋកិច្ច-នយោបាយ រចនាសម្ព័ន្ធទីផ្សារ ចង្វាក់ផលិតកម្មនិងវិនិយោគ។ ការយកចិត្តទុកដាក់ពិសេសគួរត្រូវបានផ្តល់លើការសម្របសម្រួលសហគ្រាសសហគមន៍ឬសង្គម នៅក្នុងការកែច្នៃជ័រច្បោះសម្រាប់ការប្រើប្រាស់ក្នុងស្រុក ដែលអាចកាត់បន្ថយការពឹងផ្អែកលើឈ្មួញកណ្តាល និងបង្កើតឱកាសសេដ្ឋកិច្ចផ្ទាល់សម្រាប់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។

## ១០.ឯកសារយោង


1. Arnold, J.E.M. and Ruiz Pérez, M. (1998). *The role of non-timber forest products in conservation and development. In E. Wollenberg and A. Ingles (eds.) (1998). Incomes from the forest. Methods for the development and conservation of forest products for local communities*. Bogor: CIFOR.
2. Cambodia Indigenous Peoples Organization (CIPO) (2022). *Indigenous people Data in Cambodia*. Retrieved June, 07, 2025 from https://cipocambodia.org/our-work/developing-indigenous-peoples-center/#1585208858312-76224c71-df89
3. CamboJA, (2025 May 16). *សកម្មជនបរិស្ថានបន្តរក្សាជំហរ ទោះរងការគម្រាមកំហែងផ្នែកច្បាប់បន្ទាប់ពី លាតត្រដាងករណីកាប់ឈើក្នុង ដែនជម្រកសត្វព្រៃព្រះរការ។* Retrieved May, 30, 2025 from https://opendevelopmentcambodia.net/km/news/environmental-activist-stands-firm-despite-legal-action-threat-after-exposing-logging-in-preah-roka-wildlife-sanctuary/#!/story=post-190793
4. Community Empowerment and Development Team (CEDT) & ClientEarth. (2022). *Community Protected Areas in Cambodia. Analysis of Legal Framework, Practice, and Recommendations*. Client Earth.
5. CNA, Ponlok Khmer, CIYA, GRAIN, AIPP, (2017). *Communities in Protracted Struggle Against Chinese Sugar Companies' land Grab.* Retrieved May 31, 2025 from https://grain.org/en/article/5728-

cambodia-communities-in-protracted-struggle-against-chinese-sugar-companies-land-grab

6. FAO & ICRISAT. 2015. *Community Seed Production*, by Ojiewo CO, Kugbei S, Bishaw Z & Rubyogo JC, eds. Workshop Proceedings, 9-11 December 2013. FAO, Rome & ICRISAT, Addis Ababa. 176 pp.
7. Food and Agriculture Organization (FAO) (2018). *The State of The World's Forests 2018 - Forest Pathways to Sustainable Development*. Rome. License: CC BY-NC-SA 3.0 IGO.
8. Hansen, M. C., Potapov, P. V., Moore, R., Hancher, M., Turubanova, S. A., Tyukavina, A., Thau, D., Stehman, S. V., Goetz, S. J., Loveland, T. R., Kommareddy, A., Egorov, A., Chini, L., Justice, C. O. and Townshend, J. R. G. (2013) *'High-resolution global maps of 21st-century forest cover change'*, Science 342(6160)
9. Maximo, Y.I.; Hassegawa, M.; Verkerk, P.J.; Missio, A.L. Forest Bioeconomy in Brazil: Potential Innovative Products from the Forest Sector. Land 2022, 11, 1297 from https:// doi.org/10.3390/land11081297
10. Ministry of Agriculture, Forestry and Fisheries (MAFF) (2010). National Forest Programme 2010-2029.
11. Mongabay, (2023 October 9). Communities Track a Path of Destruction Through a Cambodian Wildlife sanctuary. Retrieved May, 21, 2025 from https://news.mongabay.com/2023/10/communities-track-a-path-of-destruction-through-a-cambodian-wildlife-sanctuary/
12. Narin, Sun (2020 February 4). *Massive Chinese Sugarcane Firm Disappears from Preah Vihear.* VoA Khmer. Retrieved May, 31, 2025

from https://khmer.voanews.com/a/massive-chinese-sugarcane-firm-disappears-from-preah-vihear/5273014.html

13. Non-Timber Forest Products-Exchange Programme (NTFPs-EP). (2020). *Assessment of Policies on Non-Timber Forest Products. Country Study - Cambodia*. NTFPs-EP.

14. Phanith Chou (2022). *Livelihood Gain and Ecological Costs from Household Strategies for the Management of Non-Timber Forest Products: The Case of Phnom Prich Wildlife Sanctuary, Cambodia*. Royal University of Phnom Penh.

15. Partnership for Environment and Development (PED) (2025). *ការប្រែប្រួលវត្តមានដើមជ័រទឹកក្នុងដែនជម្រកសត្វព្រៃព្រះរការ ១ទសវត្សន៍ចុងក្រោយ, អង្គការភាពជាដៃគូដើម្បីបរិស្ថាននិងការអភិវឌ្ឍន។*

16. Ros-Tonen, M.A.F. (1999c). *Refining concepts, objectives and research questions for NTFP* (Indgenous People Data , 2022)*research. In M.A.F. Ros-Tonen (ed.) Seminar proceedings. NTFP research in the Tropenbos Programme:* results and perspectives, 28 January 1999. Wageningen: The Tropenbos Foundation.

17. Ros-Tonen, M.A.F. (2000). *The role of non-timber forest products in sustainable tropical forest management.* Holz als Roh- und Werkstoff 58: 196-201.

18. Sarah Milne, and Sango Mahanty (2015). *Conservation and Development in Cambodia: Explore Frontiers of Change in Nature, State and Society*. Routledge. Retrieved June, 10, 2025 from:

https://www.taylorfrancis.com/books/edit/10.4324/9781315887302/conservation-development-cambodia-sarah-milne-sango-mahanty

19. Sansam Plup Prey, 2022. *Personal and Household's Debt in Chhaeb, Kulen Promtep, and Prey Preah Roka Wildlife Sancturaries, Preah Vihear Province".* Retrieved May, 14, 2025 from: https://cambodia.wcs.org/saving-wild-places/northern-plains.aspx